សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការឃុំខ្លួនបណ្តោះអាសន្នក្នុង ដំណាក់កាលចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ឈុន សំបូរ**

**លីវ ដារ៉ា**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឈុន សំបូរ** និងខ្ញុំបាទឈ្មោះ **លីវ ដារ៉ា** ជានិស្សិតផ្នែកនីតិសាស្រ្តនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ឆ្នាំសិក្សា ២០១៧-២០១៨ ជំនាន់ទី ១៨ ។

ជាដំបូងខ្ញុំបាទទាំងពីរនាក់ សូមថ្លែងអំណរគុណលំអោនកាយវាចាចិត្ត និងសម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ

| | |
|---|---|
| **លោកឪពុក ឈុន ប៊ុនហៀង** | **លោកឪពុក លី គីម** |
| **អ្នកម្តាយ ឈន ច័ន្ទសោភា** | **អ្នកម្តាយ ភាវ ណៃ** |

ដែលបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ឧបត្ថម្ភរូបកូនគ្រប់បែបយ៉ាងតាំងពីតូចដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ និងបានឲ្យកូនរៀនសូត្រមានចំណេះដឹងរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។ គុណូបការៈយ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុតដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងពីរដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូបមានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។ ទង្វើរបស់លោកទាំងពីរធ្វើឲ្យកូនៗចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបាន ហើយនឹងស្ថិតក្នុងដួងព្រលឹងរបស់កូនៗជារៀងដរាបគ្មានថ្ងៃសូន្យនោះឡើយ ។

យើងទាំងពីរនាក់ក៏សូមថ្លែងអំណរគុណចំពោះ **សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីសាស្រ្តាចារ្យទាំងអស់នៃសាលកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការផ្តល់នូវពុទ្ធិល្អៗយ៉ាងពិតប្រាកដសម្រាប់ជាយាន្តបំភ្លឺជីវិតយើងខ្ញុំនៅក្នុងថ្នាក់បរិញ្ញាបត្រនេះ ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាស្រ្តាចារ្យ **ជួន ប៊ុនធី** ដែលជាសាស្រ្តាចារ្យណែនាំ ដើម្បីធ្វើឲ្យមាននូវដំណើរការនៃការតាក់តែងសារណានេះឡើងប្រកបដោយភាពជោគជ័យ។ ជាពិសេសលោកបានចំណាយនូវកម្លាំងកាយ កម្លាំងចិត្តនិងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ប្រឹងប្រែងពន្យល់ណែនាំ តម្រង់ទិស ផ្តល់ឯកសារពាក់ព័ន្ធ និងអានុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើយ៉ាងណាឲ្យសារណាយើងខ្ញុំបានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមប្រសិទ្ធិពរជ័យសិរិបវរជូនដល់ *លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តរួមថ្នាក់ និងរួមជំនាន់* ទាំងអស់សូមប្រកបតែព្រះពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

បន្ទាប់ពីបានឆ្លងកាត់ការសិក្សា និងក្រេបជញ្ជក់ចំណេះដឹងរយៈពេល ៤ឆ្នាំ នៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** យើងខ្ញុំក៏សម្រេចចិត្តជ្រើសរើសយកប្រធានបទស្ដីពី “**ការឃុំខ្លួនបណ្ដោះអាសន្នក្នុងដំណាក់កាលចៅក្រមស៊ើបសួរ**” ដែលមានលោកសាស្ត្រាចារ្យដឹកនាំលោក **ជួន ម៉ុនធី** ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ។

ការសម្រេចជ្រើសរើសប្រធានបទខាងលើមកសិក្សាស្រាវជ្រាវជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះក៏ដោយសារតែយើងខ្ញុំយល់ឃើញថា វាមានសារៈសំខាន់ណាស់ដែលអ្នកអនុវត្តនីតិវិធីនៅតាមស្ថាប័នជម្រះក្ដីទាំងអស់ត្រូវតែអនុវត្តឲ្យបានត្រឹមត្រូវ។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវនេះបានទទួលការយល់ព្រម ការឯកភាព និងការលើកទឹកចិត្តពីលោកសាស្ត្រាចារ្យដឹកនាំសរសេរសារណាក្នុងការជំរុញឲ្យកិច្ចការនេះបានសម្រេចចេញជាលទ្ធផល ។

ការស្រាវជ្រាវលើប្រធានបទនេះ ត្រូវបានចាប់ផ្ដើមដោយកសារសិក្សាឯកសារច្បាប់ ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌ សៀវភៅណែនាំរបស់ក្រសួងយុត្តិធម៌ លិខិតណែនាំរបស់ក្រសួងយុត្តិធម៌ ព្រមទាំងឯកសារ និងលិខិតបទដ្ឋានគតិយុត្តនានា ការសាកសួរយោបល់ផ្ទាល់ជាមួយចៅក្រម មេធាវី ក្រឡាបញ្ជី និងជំនួយការ មកច្របាច់បញ្ចូលគ្នា ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការអនុវត្តជាក់ស្ដែងនូវខ្លឹមសារគតិយុត្ត បញ្ហាប្រឈម ហេតុផល និងភាពខ្វះចន្លោះនៃការអនុវត្ត ។

ក្រោយពីស្រាវជ្រាវបានបញ្ចប់ ខ្ញុំបាទសង្ឃឹមថាសារណានេះនឹងក្លាយជាអត្ថបទដែលមានសារៈប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ទាំងអស់ ជាពិសេសអ្នកអនុវត្តនីតិវិធីនៅតាមស្ថាប័នជម្រះក្ដីនានា។ ជាងនេះទៅទៀត វានឹងក្លាយជាឯកសារមួយដែលបានចូលរួមចំណែក និងជំរុញដល់ការអនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាព ហើយជាចំណែកនៃការផ្សព្វផ្សាយច្បាប់ និងការស្រាវជ្រាវផ្នែកនីតិវិធីព្រហ្មទណ្ឌឲ្យកាន់តែសម្បូរបែបផងដែរ ។

បើទោះបីជាមានការខិតខំស្រាវជ្រាវ និងការត្រួតពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយ ក៏ការសរសេរសារណានេះពិតជាមានចំណុចមួយចំនួនដែលខ្វះខាត ដូចនេះយើងខ្ញុំទាំងពីនាក់រង់ចាំទទួលការរិះគន់ពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិតទាំងអស់ ដើម្បីកែលម្អសារណានេះឲ្យកាន់តែមានលក្ខណៈល្អប្រសើរ ។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** .......... ១

## ជំពូកទី១

## សញ្ញាណនៃការឃុំខ្លួនបណ្ដោះអាសន្ន

**១.១. សញ្ញាណ និងគោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន** .......... ៣

**១.១.១. សញ្ញាណទូទៅ** .......... ៣

**១.១.១.១. អត្ថន័យ និងគោលបំណង** .......... ៣

**១.១.១.២. គោលការណ៍សេរីភាពជនត្រូវចោទ** .......... ៣

**១.១.១.៣. សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ** .......... ៤

ក. សិទ្ធិស្នើសុំឲ្យបំពេញកិច្ច .......... ៥

ខ. សិទ្ធិស្នើសុំឲ្យធ្វើកោសលវិច័យ .......... ៥

គ. សិទ្ធិស្នើសុំនៅក្រៅឃុំ .......... ៦

ឃ. សិទ្ធិជ្រើសរើស ឬស្នើសុំ ឬចាត់តាំង ឬផ្លាស់ប្ដូរមេធាវី .......... ៧

ង. សិទ្ធិប្ដឹងជំទាស់ .......... ៨

ច. សិទ្ធិទទួលបានដំណឹងពីការបិទបញ្ចប់សំណុំរឿង .......... ៩

ឆ. សិទ្ធិទទួលបានដំណឹងពីដីកាដំណោះស្រាយ .......... ១០

ជ. សិទ្ធិស្នើសុំឲ្យបិទសំណុំរឿង .......... ១១

**១.១.២. គោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន** .......... ១១

**១.១.២.១. លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន** ........ ១១

ក. លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់ ........ ១២

ខ. លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ ........ ១២

គ. លក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទ ........ ១២

**១.១.២.២. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន** ........ ១២

ក. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី ........ ១៣

ខ. ដើម្បីរារាំងកុំឲ្យមានការគៀបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ........ ១៤

គ. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ........ ១៤

ឃ. ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ........ ១៥

ង. ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ ........ ១៥

ច. ដើម្បីធានារក្សាសណ្តាប់ធ្នាប់កុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស ........ ១៦

**១.២. រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន និងការពន្យារការឃុំខ្លួនបណ្តោះអាសន្ន** .... ១៧

**១.២.១. ករណីចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរ** ........ ១៧

**១.២.២. ករណីចោទប្រកាន់ពីបទឧក្រិដ្ឋផ្សេងៗ** ........ ១៧

**១.២.២.១. ករណីជនចោទប្រកាន់ជានីតិជន** ........ ១៧

**១.២.២.២. ករណីជនចោទប្រកាន់ជាអនីតិជន** ........ ១៧

**១.២.៣. ករណីចោទប្រកាន់ពីបទមជ្ឈិម** ........ ១៨

**១.២.៣.១. ករណីជនចោទប្រកាន់ជានីតិជន** ........ ១៨

**១.២.៣.២. ករណីជនចោទប្រកាន់ជាអនីតិជន** ........ ១៨

# ជំពូកទី២

# នីតិវិធីពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន


**១.១. នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន** ........................................ ១៩

**១.១.១. នីតិវិធីសម្រេចឃុំខ្លួនបណ្តោះអាសន្ន** ........................................ ១៩

**១.១.១.១. កិច្ចបង្ហាញខ្លួនលើកដំបូង** ........................................ ១៩

**១.១.១.២. កិច្ចពិភាក្សាដេញដោលចំពោះមុខ** ........................................ ២០

**១.១.១.៣. ការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន** ........................................ ២១

**១.១.១.៤. ការអនុវត្តដីកាបង្គាប់អោយឃុំខ្លួន** ........................................ ២១

**១.១.២. អានុភាពនៃការឃុំខ្លួនបណ្តោះអាសន្ន** ........................................ ២១

**១.២. ការមិនឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ** ........................................ ២២

**១.២.១. ការមិនឃុំខ្លួនបណ្តោះអាសន្ន** ........................................ ២២

**១.២.១.១. ការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន** ........................................ ២២

**១.២.១.២. ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំ** ........................................ ២២

ក. ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ ........................................ ២៣

ខ. ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំតាមបណ្តឹងរបស់ព្រះរាជអាជ្ញា ........................................ ២៣

គ. ការដោះលែងអោយនៅក្រៅឃុំតាមបណ្តឹងរបស់ជនត្រូវចោទ ........................................ ២៣

**១.២.២. ការត្រួតពិនិត្យតាមផ្លូវតុលាការ** ........................................ ២៤

**១.២.២.១. កាតព្វកិច្ចរបស់ជនត្រូវចោទ** ........................................ ២៤

**១.២.២.២. ការឃុំខ្លួនបណ្តោះអាសន្ន ករណីបំពានកាតព្វកិច្ចដាក់អោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូនតុលាការ** ........................................ ២៥

ក. រយៈពេលនៃការឃុំខ្លួន ..... ២៦

គ. ការអនុវត្តដីកាបង្គាប់អោយឃុំខ្លួន ..... ២៧

**១.២.២.៣. ការឃុំខ្លួនបណ្តោះអាសន្នក្រោយចេញដីកាដំណោះស្រាយ ..... ២៧**

**១.៣. វិធានពិសេសដែលអនុវត្តចំពោះអនីតិជន ..... ២៧**

**១.៣.១. គោលការណ៍ និងសិទ្ធិជាមូលដ្ឋានដែលអនុវត្តចំពោះអនីតិជន ..... ២៧**

**១.៣.១.១. គោលការណ៍ជាមូលដ្ឋាន ..... ២៨**

**១.៣.១.២. សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី ..... ២៨**

**១.៣.២. ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន ..... ២៩**

**១.៣.២.១. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងការដោះលែង..... ២៩**

ក. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ..... ២៩

ខ. ការដោះលែងឲ្យនៅក្រៅឃុំ ..... ៣០

**១.៣.២.២. ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ..... ៣១**

**សេចក្តីសន្និដ្ឋាន ..... ៣២**

**អនុសាសន៍ ..... ៣៤**

**ឯកសារយោង ..... ៣៦**

**បញ្ជីឧបសម្ព័ន្ធ ..... ៣៧**

# ជំពូកទី ១

# សញ្ញាណនៃការឃុំខ្លួន បណ្ដោះអាសន្ន

# ជំពូកទី២

# នីតិវិធីពាក់ព័ន្ធនឹង
# ការឃុំខ្លួន
# បណ្ដោះអាសន្ន

# សេចក្ដីសន្និដ្ឋាន

# អនុសាសន៍

# ឯកសារយោង

# ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១. បុព្វហេតុ

ស្ថាប័នតុលាការ ជាស្ថាប័នមួយដែលដើរតួនាទីដ៏សំខាន់ក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋដូចជាការចូលរួមទប់ស្កាត់នូវរាល់អំពើអសកម្មនានានៅក្នុងសង្គម។ ឯករាជ្យភាពនៃស្ថាប័ននេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ហើយជាស្ថាប័នដាច់ដោយឡែកពីស្ថាប័នដ៏ទៃទៀតរបស់រដ្ឋ ។

ប្រសិនបើយើងក្រលេកមើលតថភាពជាក់ស្តែងនៅក្នុងសង្គម បទល្មើសព្រហ្មទណ្ឌ នឹងកំពុងកើតមានជាហូរហែរ ដែលតម្រូវឲ្យតុលាការព្រហ្មទណ្ឌចូលរួមដោះស្រាយបញ្ហាក្នុងគោលបំណងដើម្បីកាត់បន្ថយបទល្មើសកុំឲ្យរីករាលដាលកាន់តែធ្ងន់ធ្ងរ។ ក្នុងដំណើរការដោះស្រាយបញ្ហានេះ តុលាការព្រហ្មទណ្ឌមាននីតិវិធីច្បាស់លាស់ដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយនៅក្នុងដំណាក់កាលស៊ើបសួរគឺផ្នែកមួយដែលមានសារៈសំខាន់ក្នុងការចូលរួមចំណែកដើម្បីផ្តល់នូវយុត្តិធម៌ព្រហ្មទណ្ឌដល់សង្គមជាតិទាំងមូល។ នៅក្នុងដំណាក់កាលស៊ើបសួរ សំណុំរឿងព្រហ្មទណ្ឌត្រូវបានគ្រប់គ្រង និងបំពេញកិច្ចដោយចៅក្រមស៊ើបសួរទាំងដោះបន្ទុកទាំងដាក់បន្ទុក ហើយក្រមនីតិវិធីព្រហ្មទណ្ឌក៏បានផ្តល់អំណាចផ្តាច់មុខដល់ចៅក្រមស៊ើបសួរដើម្បីសម្រេចពីការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ។ *ការឃុំខ្លួនបណ្តោះអាសន្ន* គឺជាវិធានការមួយដែលចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនទៅលើជនត្រូវចោទដែលមានខ្លួន និងអត្តសញ្ញាណនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ហើយជាទូទៅការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងតាមរយៈការប្តឹងសុំរបស់តំណាងអយ្យការ ឬតាមរយៈឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ ។

## ២. ចំណោទបញ្ហា

ទន្ទឹមនឹងការលើកឡើងខាងលើ មានបញ្ហា និងចម្ងល់មួយចំនួនត្រូវបានចោទឡើងពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទថា ***តើការឃុំខ្លួនបណ្តោះអាសន្ននេះធ្វើឡើងនៅពេលណា? ដើម្បីអ្វី? ហើយត្រូវគោរពតាមលក្ខខណ្ឌ និងមូលហេតុអ្វីខ្លះ? ហើយមានលំហូរនីតិវិធីយ៉ាងដូចម្តេច? ហើយតើប្រសិទ្ធភាពនៃការអនុវត្តជាក់ស្តែងក្នុងការឃុំខ្លួនបុគ្គលម្នាក់ បានគោរពយ៉ាងពេញលេញតាមការណែនាំដែលមាននៅក្នុងទ្រឹស្តីទេ?***

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសម្រេចចិត្តធ្វើការសិក្សាលើប្រធានបទ "**ការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ**" មកធ្វើការសិក្សាស្រាវជ្រាវ ក្នុងគោលបំណង ៖

- យល់ដឹងអំពីការគោរព និងធានានូវនីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្ន

- យល់ច្បាស់អំពីនីតិវិធីដើម្បីសម្រេចឃុំខ្លួនបុគ្គលម្នាក់ជាបណ្តោះអាសន្ន
- ចូលរួមលើកកម្ពស់ការអនុវត្តច្បាប់
- ចូលរួមផ្សព្វផ្សាយ និងជំរុញការស្រាវជ្រាវផ្នែកច្បាប់ ជាពិសេសដំណើរការនីតិវិធីព្រហ្មទណ្ឌឲ្យកាន់តែសំបូរបែប ។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ទាក់ទងនឹងការស្រាវជ្រាវសារណាបញ្ចប់ការសិក្សាផ្នែកបរិញ្ញាបត្រនីតិសាស្ត្រនេះ យើងខ្ញុំបានយកចិត្តទុកដាក់សំខាន់តែទៅលើចំណុចនានាដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ពោលគឺយើងខ្ញុំសូមធ្វើការសិក្សាទៅលើ *សញ្ញាណអំពីការឃុំខ្លួនបណ្តោះអាសន្ន* ព្រមទាំង *នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នដែលពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់នីតិជន និងអនីតិជន* ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវគោលបំណងនៃការស្រាវជ្រាវខាងលើ យើងបានធ្វើការសិក្សានូវឯកសារដែលមានលក្ខណៈជាទ្រឹស្តីជាច្រើនពាក់ព័ន្ធនឹងប្រធានបទ ហើយយកមកឆ្លុះបញ្ចាំងជាមួយនឹងការអនុវត្តជាក់ស្តែងតាមរយៈការចុះបំពេញការងារជាមួយនឹងមេធាវីនៅសាលាដំបូងខេត្តក្រុង។ ចំពោះប្រភពឯកសារដែលជាទ្រឹស្តីមានជាប្រភេទលិខិតបទដ្ឋានគតិយុត្ត និងសៀវភៅដែលមានដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាស សេចក្តីណែនាំ សៀវភៅសន្និសិទ្ធស្តីពីការណែនាំដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន ព្រមទាំងឯកសារគតិយុត្តផ្សេងៗទៀត។ ក្នុងនោះផងដែរ ក៏មានការចូលរួមចំណែកផ្តល់នូវដំបូន្មានល្អៗពីលោកសាស្ត្រាចារ្យដឹកនាំសារណាបញ្ចប់ការសិក្សា ចៅក្រមក្រឡាបញ្ជី មេធាវី និងជំនួយការដែលធ្លាប់មានបទពិសោធន៍អនុវត្តពាក់ព័ន្ធនឹងប្រធានបទខាងលើនេះផងដែរ ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដូចនេះជាដំណោះស្រាយ ក៏ដូចជាការឆ្លើយតបដើម្បីយល់ច្បាស់ទាក់ទងលើបញ្ហាគតិយុត្តដូចដែលបានចោទឡើងខាងលើនេះ ការសិក្សាអំពីប្រធានបទទាក់ទងនឹង "**ការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ**" យើងខ្ញុំសូមធ្វើការបកស្រាយជា ២(ពីរ)ជំពូកសំខាន់ៗ ដែលមានរួមមាន៖ **ជំពូកទី ១ សញ្ញាណនៃការឃុំខ្លួនបណ្តោះអាសន្ន** និង **ជំពូកទី២ នីតិវិធីពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន** នឹងត្រូវបានសិក្សាដូចតទៅ ៖

# ជំពូកទី១
# សញ្ញាណនៃការឃុំខ្លួនបណ្ដោះអាសន្ន

## ១.១. សញ្ញាណ និងគោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន

នីតិវិធីសម្រេចឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានមួយដែលត្រូវបានយកមកប្រើប្រាស់នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ដើម្បីទប់ស្កាត់ការប្រព្រឹត្តបទល្មើស និងធានាឲ្យបាននូវវត្តមានរបស់ជនត្រូវចោទជូនតុលាការចាត់ការតាមនីតិវិធីច្បាប់ ។

### ១.១.១. សញ្ញាណទូទៅ

ដើម្បីរក្សាជនត្រូវចោទឲ្យស្ថិតនៅក្រោមការចាត់ចែងរបស់តុលាការ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្ដល់អំណាចដល់ចៅក្រមស៊ើបសួរ ដើម្បីប្រើប្រាស់វិធានចំនួនពីរ គឺការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

#### ១.១.១.១. អត្ថន័យ និងគោលបំណង

ការឃុំខ្លួនបណ្ដោះអាសន្នគឺជាការដកហូតសិទ្ធិសេរីភាព ដោយបុគ្គលម្នាក់ត្រូវជាប់ឃុំឃាំងនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ក្រោយពេលដែលបុគ្គលនេះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌហើយត្រូវបានស្ថាប័នមានសមត្ថកិច្ចសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន នៅពេលដែលលក្ខខណ្ឌរបស់ជននេះបានបំពេញគ្រប់គ្រាន់តាមការកំណត់របស់ច្បាប់។

ការឃុំខ្លួនបណ្ដោះអាសន្នមានគោលបំណងដើម្បីទប់ស្កាត់ការកកើតនៃបទល្មើស ធានាសណ្ដាប់ធ្នាប់សុវត្ថិភាពសង្គម ជាពិសេសធានាថា បុគ្គលម្នាក់ដែលបានប្រព្រឹត្តបទល្មើសនឹងត្រូវបាននាំយកមកទទួលទោសដោយសារការប្រព្រឹត្តអំពើល្មើសរបស់ខ្លួន។

#### ១.១.១.២. គោលការណ៍សេរីភាពជនត្រូវចោទ

បើទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌបានផ្ដល់អំណាចដល់ចៅក្រមស៊ើបសួរ ក្នុងការសម្រេចឃុំខ្លួនជនត្រូវចោទយ៉ាងណាក៏ដោយ ការឃុំខ្លួននេះអាចធ្វើទៅបានតែក្នុងករណីពិសេសតែប៉ុណ្ណោះពោលគឺត្រូវប្រកាន់ខ្ជាប់ថា ជនត្រូវចោទត្រូវតែមានសេរីភាពជានិច្ច[1]។

---

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២០៣ ។

តុលាការត្រូវថ្លឹងថ្លែងអំពីមូលហេតុនានានៃការឃុំខ្លួន និងសិទ្ធិទាក់ទងនឹងសេរីភាពបុគ្គល។ សច្ចាធារណ៍នៃសេរីភាពតម្រូវឲ្យការឃុំខ្លួនមានមូលដ្ឋានលើសេចក្តីសម្រេចតាមផ្លូវតុលាការដែលសម្រេចចេញដោយអនុលោមតាមនីតិវិធី និងលក្ខខណ្ឌផ្សេងៗតាមផ្លូវច្បាប់ ដែលនេះគឺជាភាពចាំបាច់ដើម្បីឲ្យមានតុល្យភាពរវាងការឃុំខ្លួនបណ្តោះអាសន្ន និងសេរីភាពរបស់ជនត្រូវចោទ។ ជនត្រូវចោទអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នតែនៅក្រោយពេលសវនាការតទល់គ្នាតែប៉ុណ្ណោះ បើការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវបានបង្គាប់ពីសវនាការនោះទេ គេត្រូវដោះលែងជនត្រូវចោទឲ្យមានសេរីភាពឡើងវិញ។ សវនាការតទល់មានគោលបំណងខុសគ្នាពីការសួរចម្លើយជនត្រូវចោទ ជាពិសេសសវនាការតទល់គ្នាផ្តល់ឱកាសឲ្យជនត្រូវចោទធ្វើការឆ្លើយតបទៅកាន់ព្រះរាជអាជ្ញា ឯការសួរចម្លើយត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងរកការពិត និងទទួលបានកំណត់ហេតុសួរចម្លើយជនត្រូវចោទដែលអាចប្រើប្រឆាំងនឹងខ្លួនគាត់ ។

ការឃុំខ្លួនមុនសវនាការអង្គសេចក្តី គឺជាករណីលើកលែងបំផុតដែលត្រូវធ្វើក្នុងរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន។ ការឃុំខ្លួនលើសនីតិវិធី ជាការរំលោភលើគោលការណ៍សច្ចាធារណ៍នៃនិរទោសហើយការឃុំខ្លួនអាចស្របច្បាប់បានលុះត្រាតែច្បាប់មានចែងពីការឃាត់ខ្លួនចំពោះបទល្មើសដែលបានចោទប្រកាន់តែប៉ុណ្ណោះ មានន័យថាជនត្រូវចោទមិនត្រូវបានឃុំខ្លួនឡើយ បើសិនជាបទល្មើសដែគេជឿថាបានប្រព្រឹត្តនោះគឺជាបទល្មើសដែលច្បាប់របស់រដ្ឋមិនមានចែងឲ្យផ្តន្ទាទោស។ ដូចនេះដើម្បីគោរពទៅតាមគោលការណ៍សេរីភាពរបស់ជនត្រូវចោទ ការជំនុំជម្រះក្តីត្រូវតែធ្វើឡើងឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ហើយចំពោះការពន្យាពេលលើសនីតិវិធីនៅមុនពេលសវនាការ ត្រូវតែមានមូលហេតុចាំបាច់ដែលគួរឲ្យជឿទុកចិត្តបំផុត ព្រោះថាការឃុំខ្លួនជនត្រូវចោទលើសនីតិវិធីគឺជាការរំលោភបំពានសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[2]។

### ១.១.១.៣. សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ

នៅគ្រប់ដំណាក់កាលនៃនីតិវិធី ជនត្រូវចោទមានសិទ្ធិមានមេធាវីការពារឲ្យខ្លួន ជាពិសេសពេលកំពុងជាប់ឃុំខ្លួន មេធាវីអាចប្រាស្រ័យទាក់ទងដោយសេរីជាមួយជនត្រូវចោទនៅក្នុងពន្ធនាគារឬមណ្ឌលឃុំខ្លួន ហើយការប្រាស្រ័យទាក់ទងនេះត្រូវទទួលបានការការពារមិនឲ្យមានការរំខានពីអ្នកណាឡើយ[3]។ ក្រៅពីសិទ្ធិមានមេធាវី ច្បាប់បានផ្តល់សិទ្ធិមួយចំនួនទៀតដល់ជនត្រូវចោទមានដូចជាៈ

[2] សន្និសីទស្តីពីការណែនាំពីការអនុវត្តដីការសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងសាវាចរនានាស្តីពីជម្រើសផ្សេងទៀត ក្រៅពីការឃុំខ្លួន ចុះថ្ងៃទី ២៥-២៦ ខែមីនា ឆ្នាំ ២០១៤ ទំព័រ ៣៥,៣៦ និង៣៧ ។

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ១៤៩ ។

### ក. សិទ្ធិស្នើសុំឲ្យបំពេញកិច្ច

ជនត្រូវចោទដែលកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចផ្សេងៗដែលខ្លួនយល់ឃើញថាចាំបាច់ដើម្បីបញ្ជាក់ដើម្បីនត្ថិភាពនៃទោសរបស់ខ្លួនបាន ។

នៅគ្រប់ពេលនៃការស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចមួយចំនួនដូចជា៖

- ការសួរចម្លើយខ្លួន (ជនត្រូវចោទខ្លួនឯង)
- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ការស្តាប់ចម្លើយសាក្សី
- ការសួរតទល់
- ការចុះទៅកន្លែងកើតហេតុ ។[4]

ចំពោះទម្រង់នៃការស្នើសុំនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដើម្បីបញ្ជាក់ពីភាពប្រាកដច្បាស់លាស់ និងត្រូវសរសេរបញ្ជាក់ពីសំអាងហេតុឲ្យបានត្រឹមត្រូវ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងថិរវេលា ១(មួយ)ខែ បន្ទាប់ពីទទួលបានពាក្យសុំ។ ដីកានេះត្រូវតែមានសំអាង និងហេតុជូនដំណឹងជនត្រូវចោទ និងព្រះរាជអាជ្ញា ។

ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថិរវេលា ១(មួយ)ខែ នោះទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដើម្បីសម្រេចជំនួសបាន ។

### ខ. សិទ្ធិស្នើសុំឲ្យធ្វើកោសលវិច័យ[5]

ជនត្រូវចោទមានសិទ្ធិស្នើសុំចៅក្រមស៊ើបសួរឲ្យធ្វើកោសលវិច័យបាន។ ក្នុងករណីមានបញ្ហាបច្ចេកទេសកើតឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ។

ប្រសិនបើយល់ឃើញថា ការស្នើសុំនោះជាការចាំបាច់ដើម្បីបញ្ជាក់ឲ្យឃើញពីការពិត ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក[6] ចៅក្រមស៊ើបសួរនឹងសម្រេចដោយចេញ

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៣៣ ។

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៦២ ។

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៧ ។

ដីកាចាត់តាំងអ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ឬចាត់តាំងអ្នកជំនាញដែលមិនមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិឲ្យធ្វើកោសលវិច័យ។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យស្នើសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ១(មួយ)ខែ នៅក្នុងករណីនេះគឺករណីការស្នើសុំធ្វើឡើងដោយជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែបើការស្នើសុំធ្វើឡើងដោយព្រះរាជអាជ្ញា កោសលវិច័យត្រូវដាក់បញ្ចូលនៅក្នុងសំណុំរឿង។ ចៅក្រមស៊ើបសួរត្រូវកោះហៅជនត្រូវចោទ និងមេធាវី ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ ។

ចៅក្រមស៊ើបសួរត្រូវកំណត់រយៈពេលមិនឲ្យតិចជាង ១០(ដប់)ថ្ងៃ ដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ[7]។ ចំពោះទម្រង់នៃពាក្យស្នើសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យត្រូវធ្វើឡើងដោយមានសំអាងហេតុ និងជាលាយលក្ខណ៍អក្សរ។ កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យស្នើសុំកោសលវិច័យ ឬប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចដោយដីកាដោយមានសំអាងហេតុ។ ប្រសិនបើការស្នើសុំធ្វើឡើងដោយជនត្រូវចោទ ដីកាត្រូវសម្រេចក្នុងរយៈពេល ១(មួយ)ខែ និងត្រូវជូនដំណឹងដល់ជនត្រូវចោទផងដែរ។ គ្រប់ពាក្យសុំធ្វើកោលសវិច័យបន្ថែម ឬប្រតិកោសលវិច័យធ្វើឡើងក្រោយផុតរយៈពេលកំណត់ដោយចៅក្រមស៊ើបសួរត្រូវដាក់ចូលក្នុងសំណុំរឿង ។

ប៉ុន្តែបើសិនជា ចៅក្រមស៊ើបសួរមិនព្រមសម្រេចក្នុងរយៈពេលខាងលើនេះទេ ជនត្រូវចោទអាចធ្វើការប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបាន ។

### គ. សិទ្ធិស្នើសុំនៅក្រៅឃុំ

ជនត្រូវចោទអាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំគ្រប់ពេលវេលា[8]។ បន្ទាប់ពីទទួលបានពាក្យស្នើសុំនៅក្រៅឃុំនេះហើយ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនោះភ្លាមទៅព្រះរាជអាជ្ញាដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ក្រោយពីបានទទួលរួចហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់រយៈពេលនេះទេ គ្រាន់តែកំណត់រយៈពេលនៃការសម្រេចដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបញ្ជូនរឿងទៅព្រះរាជអាជ្ញា ។

---

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៧០ កថាខណ្ឌទី ៥ ។

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៧ ។

ប្រសិនបើចៅក្រមស៊ើបសួរបដិសេធពាក្យសុំនៅក្រៅឃុំរបស់ខ្លួន ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរដដែល ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១(មួយ)ខែ បន្ទាប់ពីសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ក្រោយពីបានទទួលពាក្យសុំជាថ្មីម្តងទៀត ចៅក្រមស៊ើបសួរត្រូវសម្រេចលើពាក្យសុំនេះក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីទទួល។ រីឯសភាស៊ើបសួរក្រោយពីបានទទួលពាក្យស្នើសុំនៅក្រៅឃុំរបស់ជនត្រូវចោទហើយត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ ដូចចៅក្រមស៊ើបសួរដែរ។

ប៉ុន្តែបើសិនជា ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃទេ ជនត្រូវចោទអាចដាក់ពាក្យប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

### ឃ. សិទ្ធិជ្រើសរើស ឬស្នើសុំ ឬចាត់តាំង ឬផ្លាស់ប្តូរមេធាវី

ជនត្រូវចោទដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន មានសិទ្ធិជ្រើសរើសមេធាវីបានក្នុងករណីមិនទាន់បានជ្រើសរើស ឬអាចស្នើសុំមេធាវីក្នុងករណីខ្លួនពុំមានលទ្ធភាព ឬមេធាវីត្រូវបានចាត់តាំងដោយតុលាការ ហើយគាត់ក៏អាចធ្វើការផ្លាស់ប្តូរមេធាវីបានដែរ ។

***សិទ្ធិជ្រើសរើសមេធាវី*** នៅក្នុងករណីមុនពេលដែលការឃុំខ្លួនបណ្តោះអាសន្នត្រូវបានធ្វើឡើង ប្រសិនបើជនត្រូវចោទពុំទាន់បានជ្រើសរើសមេធាវីនៅឡើយ ខ្លួនអាចជ្រើសរើសមេធាវីដែលជាសមាជិកគណៈមេធាវីដើម្បីការពារសិទ្ធិឲ្យខ្លួនបាន។

***សិទ្ធិស្នើសុំមេធាវី*** ការស្នើសុំមេធាវីអាចធ្វើទៅបានប្រសិនបើជនត្រូវចោទជាជនក្រីក្រដែលគ្មានលទ្ធភាព។ ការស្នើសុំនេះ គឺត្រូវធ្វើឡើងដោយការស្នើសុំទៅកាន់គណៈមេធាវីដែលទទួលបន្ទុកការពារជនក្រីក្រ ឬមួយតាមបណ្តាអង្គការក្រៅរដ្ឋាភិបាលផ្សេងៗដែលមានផ្តល់ជំនួយផ្នែកច្បាប់ជាពិសេសសេវាមេធាវីដោយឥតគិតថ្លៃ ។

***សិទ្ធិទទួលបានការចាត់តាំងមេធាវីដោយតុលាការ*** ជាការចាំបាច់ក្នុងករណីពិសេសមួយចំនួន។ បន្ទាប់ពីទទួលដំណឹងអំពីសិទ្ធិជ្រើសរើសមេធាវី និងសិទ្ធិស្នើសុំមេធាវី មេធាវីក៏អាចត្រូវបានចាត់តាំងដោយតុលាការផងដែរ ។ នៅក្នុងដំណាក់កាលនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ករណីជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[9]។ ករណីនៅក្នុងដំណាក់កាលជំនុំជម្រះ ជំនួយមេធាវីត្រូវតែមានជាដាច់ខាតនៅក្នុងករណីជនជាប់ចោទជា អនីតិជន ឬករណីបទល្មើសជាបទល្មើសឧក្រិដ្ឋ ។ បើទោះបីជាជនជាប់ចោទគ្មានលទ្ធភាពក្នុងការជ្រើសរើស

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៤៣ កថាខណ្ឌទី៤ ។

មេធាវីក៏ដោយ ក៏មេធាវីត្រូវបានចាត់តាំងតាមគំនិតផ្តើមរបស់ប្រធានតុលាការនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខខន្តិកៈមេធាវី[10] ។

**ង. សិទ្ធិប្តឹងជិតចិត្ត**

***ការប្តឹងជិតចិត្ត*** គឺជាសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងបដិសេធវត្តមានរបស់ចៅក្រមអាសនៈដោយពុំអនុញ្ញាតកុំឲ្យគាត់ទទួលបន្ទុករឿងក្តីណាមួយ។ ចៅក្រមនៅទីនេះ គឺសំដៅទៅលើ *ចៅក្រមអាសនៈ* ដែលមិនសំដៅទៅដល់ចៅក្រមខាងផ្នែកអយ្យការឡើយ។ ចៅក្រមអាសនៈនៅក្នុងនីតិវិធីព្រហ្មទណ្ឌអាចជា **ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះ** ។

បណ្តឹងជិតចិត្ត អាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈតែប៉ុណ្ណោះ[11]។ ចំពោះមូលហេតុនៃការប្តឹងជិតចិត្ត មានដូចខាងក្រោមដែលត្រូវបានច្បាប់កំណត់យ៉ាងជាក់លាក់នៅក្នុងមាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌៈ

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតរបស់សហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយនៅក្នុងរឿងក្តី
- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ឬញាតិពន្ធដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធដល់ថ្នាក់ទី៣ របស់ភាគីណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្តី
- កាលណាចៅក្រមជា ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្តី ឬ
- កាលណាចៅក្រមបានចូលរួមក្នុងនាមជាមជ្ឈត្តករក្នុងរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅសាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី ។

អំពីមូលហេតុនៃការប្តឹងជិតចិត្ត គឺក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់សម្រាប់គូភាគី (ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី) អាចប្តឹងជិតចិត្តបាន។ ក្រៅពីការប្តឹងជិតចិត្តច្បាប់ក៏ទុកសិទ្ធិដល់ចៅក្រមក្នុងការដកខ្លួនពីរឿងក្តីផងដែរ។ ចៅក្រមដែលមានមូលហេតុត្រឹមត្រូវមិនព្រមចូលរួម

---

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ៣០១ ។

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ៥៥៦ កថាខណ្ឌទី១ ។

ក្នុងការស៊ើបសួរ ឬជំនុំជម្រះរឿងក្តីណាមួយនោះអាចសុំឲ្យគេជំនួសខ្លួនបាន[12]។ ចៅក្រមដែលមានបំណងចង់ដកខ្លួននោះត្រូវធ្វើពាក្យសុំ ពាក្យសុំនោះត្រូវដាក់ជូនប្រធានតុលាការរបស់ខ្លួនដើម្បីសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យដកខ្លួន។ សូមបញ្ជាក់ផងដែរថា សេចក្តីសម្រេចរបស់ប្រធានតុលាការមិនអាចតវ៉ាបានឡើយ ។

ការកំណត់បែបនេះ គឺក្នុងគោលបំណងជាការការពារសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីរបស់ខ្លួនប្រកបទៅដោយភាពយុត្តិធម៌។ ចៅក្រមអាចធ្វើការស្វែងរកយុត្តិធម៌បានលុះត្រាណាតែគាត់អាចជៀសវាងនូវ **អគតិទាំង៤** និងធានារក្សាឲ្យបាននូវ **គតិទាំង៥**[13] ។

ជនត្រូវចោទដែលចង់ប្តឹងជំទាស់ចៅក្រមអាសនៈណាមួយ ត្រូវជូនពាក្យប្តឹងតាំងពីពេលដែលខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជំទាស់ បើពុំដូច្នេះទេមិនអាចទទួលបានឡើយ។ ប៉ុន្តែនៅក្រោយពេលបិទការពិភាក្សាដេញដោលពាក្យប្តឹងជំទាស់ចៅក្រមមិនអាចធ្វើបានឡើយ[14] ។

### ច. សិទ្ធិទទួលបានដំណឹងពីការបិទបញ្ចប់សំណុំរឿង

កាលណាចៅក្រមស៊ើបសួរ យល់ឃើញថាការស៊ើបសួរបានបញ្ចប់ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីប្រសិនបើមាន[15] ។ នៅពេលដែលមានការជូនពត៌មានអំពីការបិទការស៊ើបសួរនេះក្រមនីតិវិធីព្រហ្មទណ្ឌបានទុកសិទ្ធិឲ្យព្រះរាជអាជ្ញាក្នុងការស្នើសុំឲ្យចៅក្រមស៊ើបសួរក្នុងការបំពេញកិច្ចណាមួយ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើការស៊ើបសួរថ្មីនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២ (ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា) នៃក្រមព្រហ្មទណ្ឌ ។

***ប៉ុន្តែចំពោះជនត្រូវចោទវិញ តើគាត់អាចមានសិទ្ធិស្នើសុំឲ្យបំពេញកិច្ចដូចព្រះរាជអាជ្ញាដែលមានចែងនៅក្នុងមាត្រា ១៣៣ (ការស្នើសុំឲ្យបំពេញកិច្ចដោយជនត្រូវចោទ) បានដែរ ឬទេ ?***

អំពីបញ្ហានេះមានការបកស្រាយផ្សេងៗគ្នាពីសំណាក់សិស្សនិស្សិត សាស្ត្រាចារ្យ ឬពីសំណាក់អ្នកអនុវត្តច្បាប់។ មានមតិពីរនៃការយល់ឃើញអំពីបញ្ហានេះដោយៈ

---

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ៥៥៥ ។

[13] ហ៊ែល ចំរើន, *មរតកយុត្តិធម៌ខ្មែរ* (ភ្នំពេញ៖ បោះពុម្ពផ្សាយដោយរោងពុម្ព ភ្នំពេញ, ឆ្នាំ២០១០), ទំព័រទី ២៩៧ ដល់ទំព័រទី ៣០០ ។

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ៥៥៧ ។

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៤៦ កថាខណ្ឌទី១ ។

***មតិទីមួយ៖*** យល់ឃើញថាជនត្រូវចោទមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចដូចដែលមានចែងនៅក្នុងមាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន។

***មតិទីពីរ៖*** បកស្រាយថានៅពេលដែលចៅក្រមស៊ើបសួរជូនដំណឹងដល់ជនត្រូវចោទអំពីការបិទការស៊ើបសួរហើយ ជនត្រូវចោទពុំអាចស្នើសុំឲ្យបំពេញកិច្ចដូចមានចែងនៅក្នុងមាត្រា ១៣៣ បានឡើយ មានន័យថាបើគាត់ចង់ស្នើសុំឲ្យបំពេញកិច្ចដូចមានចែងនៅក្នុងមាត្រានេះគាត់ត្រូវស្នើសុំឲ្យបានមុនការជូនដំណឹងអំពីការបិទការស៊ើបសួរ។

**អំពីបញ្ហានេះ ប្រាកដជាមានចម្ងល់ហើយថាបើសិនជាមិនអនុញ្ញាតឲ្យជនត្រូវចោទស្នើសុំឲ្យបំពេញកិច្ចតាមបញ្ញត្តិនៃមាត្រា ២៤៦ ចាំបាច់ជូនដំណឹងដល់គាត់ធ្វើអ្វី?**

***មតិទីពីរបានបកស្រាយបន្ថែមថា៖*** វាគ្រាន់តែជាការជូនដំណឹងឲ្យដល់ជនត្រូវចោទឲ្យបានដឹងតាមការកំណត់របស់ច្បាប់តែប៉ុណ្ណោះ ។

### ឆ. សិទ្ធិទទួលបានដំណឹងពីដីកាដំណោះស្រាយ

បន្ទាប់ពីការជូនពត៌មានអំពីការបិទការស៊ើបសួរ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថាការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ នៅក្នុងសេចក្តីសន្និដ្ឋានស្ថាពរនេះ ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់[16] ។

ក្រោយពីធ្វើដីកាសន្និដ្ឋានស្ថាពររួច ព្រះរាជអាជ្ញាត្រូវបញ្ជូនដីកានោះដោយភ្ជាប់ជាមួយសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរ។ បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានស្ថាពររួច ចៅក្រមស៊ើបសួរត្រូវធ្វើដីកាដំណោះស្រាយ ដីកានេះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ឬដីកាបញ្ជូនឲ្យសម្រេចរឹបអូស[17]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការធ្វើដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ[18]។

---

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា២៤៦ កថាខណ្ឌទី ៥ ។

[17] ច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤៧ មាត្រា៣៧២ និងមាត្រា៣៨២, ០៩ មិថុនា ២០១៣, មាត្រា ២៤៧ ។

[18] ច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤៧ មាត្រា៣៧២ និងមាត្រា៣៨២, ០៩ មិថុនា ២០១៣, មាត្រា ២៤៧ កថាខណ្ឌទី ៤ ។

ក្រោយពីការធ្វើដីកាដំណោះស្រាយរួច ដីកានោះត្រូវជូនដំណឹងដល់ជនត្រូវចោទក្នុងរយៈពេលដ៏ខ្លីបំផុត។ ចំពោះរយៈពេលដ៏ខ្លីនេះច្បាប់មិនបានកំណត់ជាក់លាក់នោះទេ ប៉ុន្តែចៅក្រមត្រូវគិតគូពីរយៈពេលដែលសមរម្យ ។

មានសំណួរចោទឡើងថា ***ក្រោយពីបានទទួលដំណឹងពីដីកាដំណោះស្រាយរួច តើជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍ចំពោះដីកានេះបានដែរ ឬទេ?***

បើពិនិត្យនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ *ជំពូកទី២ មាត្រា ២៦៧ បណ្ដឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ* ពុំមានចំណុចណាមួយអនុញ្ញាតឲ្យជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយឡើយ ទោះជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ឬដីកាបញ្ជូនឲ្យសម្រេចរឹបអូសក៏ដោយ។ ប៉ុន្តែចំពោះដើមបណ្ដឹងរដ្ឋប្បវេណីវិញ ការប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយដូចមានចែងនៅក្នុងមាត្រា ២៤៧ (ដីកាដំណោះស្រាយ) គឺអាចធ្វើបាន[19] ។

### ជ. សិទ្ធិស្នើសុំឲ្យបិទសំណុំរឿង[20]

នៅពេលផុតចិរវេលា ១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចោទប្រកាន់ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ។ នៅក្នុងរយៈពេល ១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ បើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេលនេះទេ ជនត្រូវចោទអាចប្ដឹងទៅសភាស៊ើបសួរដែលធ្វើអធិបញ្ញាឲ្យចៅក្រមស៊ើបសួរសម្រេច។ នោះជាសិទ្ធិមួយដែលផ្ដល់ដោយក្រមនីតិវិធីព្រហ្មទណ្ឌដល់ជនត្រូវចោទ ដើម្បីជៀសវាងការខ្ជីខ្ជារបស់ចៅក្រមស៊ើបសួរដែលអាចកើតមានឡើង ។

អំណាចដែលទទួលស្គាល់អំពីការប្ដឹងសុំបិទសំណុំរឿងដល់ជនត្រូវចោទនេះ អាចត្រូវបានប្រើប្រាស់ដោយមេធាវីរបស់ជនត្រូវចោទបាន[21] ។

## ១.១.២. គោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន

### ១.១.២.១. លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន

តាមគោលការណ៍សេរីភាពរបស់ជនត្រូវចោទ ការឃុំខ្លួនបណ្ដោះអាសន្នអាចប៉ះពាល់ខ្លាំង

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា២៦៨ ទ្រទី៩ ។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា២៨៦ ។

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា២៨៦ កថាខណ្ឌទី៣ ។

ដល់សេរីភាពរបស់ជននោះ ហេតុដូច្នេះហើយចៅក្រមស៊ើបសួរត្រូវពិចារណាឲ្យបានច្បាស់លាស់ពិសេសអំពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្នដែលរួមមាន **(ក) លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់ (ខ) លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ (គ) លក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទ** ។

**ក. លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់**

តាមខ្លឹមសារមាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម មានន័យថាលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើបានតែក្នុងករណីនៃការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមតែប៉ុណ្ណោះ ពោលគឺមិនអាចអនុវត្តបាននៅក្នុងករណីបទលហុនោះទេ។ ការចោទប្រកាន់នេះសំដៅទៅលើការចោទប្រកាន់ដែលធ្វើឡើងដោយអង្គការអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ច ។

**ខ. លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ**

ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណី ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ) ឆ្នាំ[22]។ ចំណុចនេះបានបញ្ជាក់អំពីគោលការណ៍ច្បាប់ដែលបានកំណត់លក្ខខណ្ឌនៃទោសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ដោយមិនគិតពីទោសពិន័យឡើយ នៅពេលចៅក្រមស៊ើបសួរវាយតម្លៃបានពីភស្តុតាង ដែលជនត្រូវចោទនឹងប្រឈមលើការផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ) ឆ្នាំឡើងទៅក្នុងសំណុំរឿងដែលខ្លួនទទួលបាន និងត្រូវពិចារណាអំពីការសម្រេចឃុំខ្លួយនបណ្តោះអាសន្ន ចំពោះជនត្រូវចោទ ។

**គ. លក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទ**

ក្រៅពីលក្ខខណ្ឌនៃបទល្មើស និងលក្ខខណ្ឌនៃទោស ក៏នៅមានលក្ខខណ្ឌដែលទាក់ទងនឹងអាយុរបស់ជនត្រូវចោទ ដែលចៅក្រមស៊ើបសួរត្រូវពិចារណាផងដែរមុននឹងសម្រេចឃុំខ្លួនជននោះជាបណ្តោះអាសន្ន ដោយហេតុថា **"អនីតិជនអាយុតិចជាង ១៤ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នបាននោះទេ"**[23] ។

**១.១.២.២. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន**

ក្រៅពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលបានបំពេញរួចហើយ ដើម្បីសម្រេចធ្វើ

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២០៤ ទំព័រទី៧៣ ។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា ២១២ ទំព័រទី៧៦ ។

ការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬច្រើនដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចឃុំខ្លួនបុគ្គលណាម្នាក់ជាបណ្តោះអាសន្ន ដោយពន្យល់បង្ហាញពីសំអាងហេតុសម្រាប់គាំទ្រទៅនឹងមូលហេតុនីមួយៗ ដែលបានលើកឡើង ឬមិនត្រូវយកមកអនុវត្ត មានជាអាទិ៍ដូចតទៅ៖ (ក) **ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី (ខ) ដើម្បីរារាំងកុំឲ្យមានការគៀបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត (គ) ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ (ឃ) ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី (ង) ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ (ច) ដើម្បីធានារក្សាសណ្តាប់ធ្នាប់កុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស ។**

## ក. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី

ជាធម្មតាសកម្មភាពនៃបទល្មើសមិនដូចគ្នាទេ បទល្មើសមួយចំនួនមានលក្ខណៈស្រាល និងបង្កព្យសនកម្មតិចតួច តែបទល្មើសខ្លះមានលក្ខណៈសាហាវឃោរឃៅ និងបណ្តាលឲ្យមានព្យសនកម្មធ្ងន់ធ្ងរ បង្កឲ្យប៉ះពាល់ដល់សន្តិសុខសង្គម និងអាចមានការប៉ះពាល់ដល់អាយុជីវិតជនរងគ្រោះជាច្រើននាក់។ ក្រោយពេលដែលជនត្រូវចោទបានប្រព្រឹត្តបទល្មើសណាមួយ ហើយត្រូវបានឃាត់ខ្លួននោះ ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលលទ្ធភាពនៃការកើតឡើងវិញនៃបទល្មើស ឬការរាលដាលនៃបទល្មើសបន្តទៀត ពីព្រោះករណីខ្លះ ប្រសិនបើជនល្មើសមិនត្រូវបានឃុំខ្លួនទេ នោះអាចនឹងមានលទ្ធភាពនៃការបន្តសកម្មភាពល្មើសទៀតបាន។ *ឧទាហរណ៍៖* ករណីប៉ុនប៉ងឃាតកម្មមួយ ក្រោយពីមានតម្រុយ និងភស្តុតាងដែលបញ្ជាក់ថាបុគ្គលម្នាក់ពិតជាបានប្រព្រឹត្តអំពើប៉ុនប៉ងមែន ការសម្រេចឃុំខ្លួនជាការចាំបាច់ដើម្បីបញ្ចប់បទល្មើសត្រឹមនេះ ចៀសវាងការនៅក្រៅឃុំអាចផ្តល់ឱកាសឲ្យជននោះទៅសម្លាប់ជនរងគ្រោះដើម្បីបំពេញបំណងរបស់ខ្លួន ទោះបីជាខ្លួនប្រឈមនឹងការផ្តន្ទាទោសពីតុលាការតាមច្បាប់ក៏ដោយ ។

ហេតុដូច្នេះ ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបនៃការឃុំខ្លួនអាចបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី ថាតើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើសដែលខ្លួនត្រូវចោទឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មី ឬទេ[24] ?

[24] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់ឲ្យប្រើប្រាស់បមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្តីសម្រេច លេខ៦ ចំណុច ក ។

**ខ. ដើម្បីរារាំងកុំឲ្យមានការគៀបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត**

បទល្មើសខ្លះ មានការចូលរួមប្រព្រឹត្តពីមនុស្សច្រើនគ្នា អាចជាអ្នកប្រព្រឹត្តដោយផ្ទាល់(ចារី) ជាសហចារី អ្នកសមគំនិត និងអ្នកផ្ដើមគំនិត ជាដើម។ សកម្មភាពល្មើសទាំងនេះអាចមានជនរងគ្រោះ ឬសាក្សីបានឃើញផ្ទាល់ភ្នែក ហើយសាក្ខីរបស់សាក្សីនោះ ជាភស្តុតាងដ៏សំខាន់សម្រាប់បង្ហាញការពិតនៃអង្គហេតុទាំងមូល។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចឃុំខ្លួនជនត្រូវចោទទេ នោះជនត្រូវចោទអាចទៅគំរាមកំហែងសាក្សី ឬជនរងគ្រោះតាមវិធីផ្សេងៗមិនឲ្យឆ្លើយការពិតនៅចំពោះមុខតុលាការ ហេតុដូច្នេះការឃុំខ្លួនជាការចាំបាច់។ ដូចគ្នាដែរជនត្រូវចោទ និងអ្នកចូលរួមប្រព្រឹត្តបទល្មើសផ្សេងទៀតអាចត្រូវរ៉ូវគ្នាទៅបំផ្លាញភស្តុតាងតាមមធ្យោបាយផ្សេងៗរបស់ពួកគេ។ *ឧទាហរណ៍៖* មានអំពើហិង្សារវាងយុវជនមួយក្រុមដោយប្រើដំបង និងខ្សែក្រវាត់បណ្ដាលឲ្យជនរងគ្រោះរបួសធ្ងន់។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចឃុំខ្លួនបណ្ដោះអាសន្នទេ នោះជនត្រូវចោទ និងអ្នកសមគំនិតអាចត្រូវរ៉ូវគ្នា និងអាចមានការគៀបសង្កត់សាក្សី ឬជនរងគ្រោះដែលជាឧបសគ្គក្នុងការស្វែងរកការពិត និងធានាមិនឲ្យខូចខាតដល់កិច្ចស៊ើបសួរ ។

ហេតុដូច្នេះ ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរារាំងដល់ការគៀបសង្កត់សាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត ថាតើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចគៀបសង្កាត់សាក្សី ឬជនរងគ្រោះឬទេ? តើជនសមគំនិតនៅតែមានសេរីភាពឬទេ (មិនបារម្ភពីការត្រូវរ៉ូវគ្នាទេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួន)[25] ?

**គ. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ**

ជាទូទៅក្រោយពីមានហេតុការណ៍ណាមួយកើតមានឡើង ក្រៅពីសាក្សី និងជនរងគ្រោះដែលបានឃើញ បានឮអង្គហេតុផ្ទាល់ក៏នៅមានភស្តុតាង ឬតម្រុយជាសម្ភារៈផ្សេងៗទៀត ដែលអាចបញ្ជាក់ពីការពិតនៃអង្គហេតុបាន ហើយតួនាទីរបស់ចៅក្រមស៊ើបសួរ គឺស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកដើម្បីបញ្ជាក់នូវការពិត។ ប្រសិនបើភស្តុតាងត្រូវបានលុបបំបាត់នោះការពិតវាប្រាកដជាពិបាកនឹងអាចរកឃើញ ហើយយុត្តិធម៌ក៏ត្រូវបាត់បង់ទៅតាមនោះដែរ ហេតុដូច្នេះការឃុំខ្លួនបណ្ដោះអាសន្នជាករណីចាំបាច់ដើម្បីធានាឲ្យបានថា ជនត្រូវចោទមិនមានលទ្ធភាពទៅបំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈផ្សេងៗ។ *ឧទាហរណ៍* ករណីបទល្មើសជួញដូរគ្រឿងញៀន

[25] លិខិតលេខ ១២០ កយ.របូ/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្ដីសម្រេច លេខ២៦ ចំណុច ខ ។

ដើម្បីធានាថាជនត្រូវចោទមិនអាចត្រឡប់ទៅបំផ្លាញវត្ថុតាងដែលជាគ្រឿងញៀន ដែលខ្លួនបានលាក់ទុកនៅកន្លែងដែលមានសមត្ថកិច្ចរកមិនឃើញ ហើយនៅមានការសង្ស័យថាអាចនៅមានវត្ថុតាងបន្ថែមទៀត ដូច្នេះការឃុំខ្លួនបណ្ដោះអាសន្នជាករណីចាំបាច់បំផុត ដោយសារវត្ថុតាងនៅក្នុងករណីនៃបទល្មើសជួញដូរគ្រឿងញៀននេះមានសារៈសំខាន់ណាស់ ព្រោះការសម្រេចទោសផ្អែកលើបរិមាណសារធាតុសុទ្ធ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

ហេតុនេះចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរារាំងជនត្រូវចោទពីការធ្វើឲ្យខូចខាតភស្តុតាង ឬតម្រុយជាសម្ភារៈ ថាតើនៅតែមានភស្តុតាង ឬតម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈ(ឧទាហរណ៍៖ អាវុធដែលពាក់ព័ន្ធជាមួយបទល្មើសជាដើម)[26] ?

### ឃ. ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី

ការសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន គឺជាការសំខាន់ណាស់ពីព្រោះថាប្រសិនទុកជននេះឲ្យនៅក្រៅឃុំ ជននេះអាចរត់គេចខ្លួនដើម្បីចៀសវាងពីការទទួលខុសត្រូវនូវអំពើល្មើសរបស់ខ្លួន។ *ឧទាហរណ៍* ជនត្រូវចោទជាពាណិជ្ជករល្បីរកស៊ីចេញចូលក្រៅប្រទេស ហើយមានទីលំនៅនៅបរទេសថែមទៀត ប្រសិនបើមិនឃុំខ្លួនគាត់ជាបណ្ដោះអាសន្នទេ គាត់អាចរត់ទៅក្រៅប្រទេសដើម្បីគេចវេសពីការទទួលខុសត្រូវតាមផ្លូវច្បាប់ ។

ហេតុដូចនេះ ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានរបស់ជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធីថា តើមានហេតុផលសមរម្យដើម្បីជឿជាក់ថាជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅនៅក្រៅប្រទេសដែរឬទេ[27] ?

### ង. ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ

ជាធម្មតាអំពើល្មើសតែងតែបង្កឲ្យមានព្យសនកម្ម ហើយជនរងគ្រោះក្រុមគ្រួសាររបស់ជនរងគ្រោះ និងអ្នកដែលបានដឹងអំពីហេតុការណ៍នេះ តែងមានអារម្មណ៍ឈឺចាប់ និងពោរពេញទៅដោយកំហឹងរហូតឈានទៅដល់ការសងសឹកទៀតផង។ តែការសងសឹកក្រៅប្រព័ន្ធតុលាការបែបនេះ មិនស្របច្បាប់ទេ វាអាចបន្តគំនុំ និងចងអាឃាតគ្នាមិនចេះចប់មិនចេះហើយ ជាពិសេសវាធ្វើឲ្យសង្គមជាតិទាំងមូលគ្មានរបៀបរៀបរយ និងគ្មានសេចក្ដីថ្លៃថ្នូរ។ *ឧទាហរណ៍ជាក់ស្ដែង* នៅក្នុង

[26] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្ដីសម្រេច លេខ៦ ចំណុច គ ។

[27] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្ដីសម្រេច លេខ៦ ចំណុច ឃ ។

សារពត៌មាន និងបណ្តាញសង្គមផ្សេងៗ ករណីលួច ឆក់ ប្លន់ ទ្រព្យសម្បត្តិប្រជាពលរដ្ឋ ជនល្មើស តែងតែត្រូវបានពួកគាត់វាយដំបណ្តាលឲ្យរងរបួសយ៉ាងធ្ងន់ធ្ងរ ពេលខ្លះស្ទើរតែបាត់បង់ជីវិតក៏មានដែរ។ ម្យ៉ាងទៀត ដូចជាករណីឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ **នួន ជា** មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ មូលហេតុនៃការការពារសុវត្ថិភាពរបស់ជនត្រូវចោទ ក៏ត្រូវបានចៅក្រមស៊ើបសួរនៃសាលាក្តីខ្មែរក្រហម យកមកធ្វើជាសំអាងហេតុនៃសេចក្តីសម្រេចឃុំខ្លួនរូបគាត់ផងដែរ។ ដូចនេះ ដើម្បីចៀសវាងចៀសវាងនូវការប្រើហិង្សា ឬការប៉ះពាល់ដល់សន្តិសុខលើជនត្រូវចោទ ការសម្រេចឃុំខ្លួនបណ្តោះអាសន្នាជាការចាំបាច់បំផុត ។

ជារួមមកចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចការពារសន្តិសុខឲ្យជនត្រូវចោទថាតើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទដែរឬទេ[28] ?

### ច. ដើម្បីធានារក្សាសណ្តាប់ធ្នាប់កុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស

បទល្មើសដែលកើតមានឡើងនៅក្នុងសង្គម តែងតែមានលក្ខណៈប្លែកៗពីគ្នា បទល្មើសខ្លះបណ្តាលឲ្យមានមនុស្សរងគ្រោះថ្នាក់ជាច្រើននាក់ ហើយសង្គមទាំងមូលអាចជួបប្រទះភាពច្របូកច្របល់រឹកររជាអាទិ៍ *អំពើភេរវកម្ម ការជួញដូរគ្រឿងញៀន ឬបទឧក្រិដ្ឋកម្មសង្គ្រាម ជាដើម*។ បទល្មើសទាំងនេះមានការលំបាកក្នុងការបង្ក្រាប ទប់ស្កាត់ និងអាចបង្កឲ្យមានចលាចលនៅក្នុងប្រទេស បង្កឲ្យមានការភ័យខ្លាចដល់ប្រជាជន ហេតុដូច្នេះ ការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ជាការចាំបាច់ណាស់ដើម្បីបញ្ចៀសនូវផលប៉ះពាល់ធ្ងន់ធ្ងរ ដែលអាចកើតមានឡើងជាបន្តទៀត។ *ឧទាហរណ៍* ដូចជាបទល្មើសដែលពាក់ព័ន្ធនឹងអំពើគុបកម្ម អំពើជួញដូរមនុស្ស ការធ្វើអបគមន៍ជាដើម ។

ជារួមមក ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ[29] ។

---

[28] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្តីសម្រេច លេខ៦ ចំណុច ង ។

[29] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្តីសម្រេច លេខ៦ ចំណុច ច ។

## ១.២. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន និងការពន្យាការឃុំខ្លួនបណ្ដោះអាសន្ន

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ការសម្រេចនេះត្រូវស្ថិតនៅក្នុងថិរវេលាដែលកំណត់ដោយច្បាប់។ ហើយបន្ទាប់ថិរវេលាដែលថិរវេលាបានកន្លងផុតទៅចៅក្រមស៊ើបសួរក៏អាចពន្យាការឃុំខ្លួនជនត្រូវចោទបានផងដែរ ដោយទាំងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន និងថិរវេលានៃការពន្យាការឃុំខ្លួននេះប្រែប្រួលទៅតាមប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទដែលបានឃុំខ្លួន។ ចំពោះថិរវេលានៃការឃុំខ្លួន និងការពន្យាការឃុំខ្លួនមានបង្ហាញដូចតទៅ៖

### ១.២.១. ករណីជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរ

ក្នុងករណីនេះ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី១(មួយ) ឆ្នាំបានទេចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន១(មួយ) ឆ្នាំ ដោយដីកាសម្រេចមានសំអាងហេតុ ហើយការពន្យាពេលនេះអាចធ្វើបានតែ ២ (ពីរ) ដងគត់[30] ។

### ១.២.២. ករណីជាប់ចោទពីបទឧក្រិដ្ឋផ្សេងៗ

#### ១.២.២.១. ករណីជនជាប់ចោទជានីតិជន

ករណីបើជនត្រូវចោទជានីតិជន នោះថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នគឺមានរយៈពេល ៦ខែ ហើយអាចពន្យាពេលបាន ៦ខែទៀត ចំនួនពីរដង[31] ។

#### ១.២.២.២. ករណីជនជាប់ចោទជាអនីតិជន

ក្នុងករណីដែលជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី **១៤ឆ្នាំ** ដល់ **១៦ឆ្នាំ** នោះរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ខែបាននោះទេ[32] ។

ដោយឡែកនៅក្នុងករណីដែលជនត្រូវចោទជាអនីតិជនដែលមានអាយុចាប់ពី **១៦ឆ្នាំ** ដល់ក្រោម **១៨ឆ្នាំ** នោះរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ខែបាននោះទេ[33] ។

---

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១០ ។

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២០៨ ។

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១៣ ។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១៣ ។

### ១.២.៣. ករណីជាប់ចោទពីបទមជ្ឈិម

#### ១.២.៣.១. ករណីជនជាប់ចោទជានីតិជន

ចំពោះអនីតិជនដែលជាប់ចោទពីបទមជ្ឈិម រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នគឺ ៤ខែ ហើយអាចពន្យាពេលបាន ២ខែទៀត តែម្ដងគត់ ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[34]។ *ឧទាហរណ៍* ជនត្រូវចោទជាប់ចោទពីបទ **លួច** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ដល់៣ឆ្នាំ (មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ) អប្បបរមានៃទោស គឺ៦ខែ ដូចនេះពាក់កណ្ដាលនៃអប្បបរមាគឺ ៣ខែ។ មានន័យថា ការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវឲ្យលើសពី ៣ខែឡើយ។ ចំណែកឯបទល្មើស **ទទួលផលចោរកម្ម** វិញ ត្រូវបានច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ (មាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ)។ ហេតុនេះពាក់កណ្ដាលនៃអប្បបរមានៃទោសគឺ ១ឆ្នាំ។ ដូច្នេះមានន័យថា ការឃុំខ្លួនបណ្ដោះអាសន្នគឺ ៤ខែ ហើយចៅក្រមស៊ើបសួរអាចពន្យាពេលបានបន្ថែម ២ខែទៀតតែម្ដងគត់ជាសរុបមិនឲ្យលើសពី ៦ខែឡើយ (ក្នុងករណីនេះ ៦ខែ គឺតិចជាង ១ឆ្នាំដែលជាចំនួនពាក់កណ្ដាលនៃអប្បបរមានៃទោសដែលកំណត់ដោយច្បាប់សម្រាប់បទ ទទួលផលចោរកម្ម) ។

#### ១.២.៣.២. ករណីជនជាប់ចោទជាអនីតិជន

ក្នុងករណីដែលជនត្រូវចោទជាអនីតិជនអាយុចាប់ពី **១៤ឆ្នាំ** ដល់ក្រោម **១៦ឆ្នាំ** រយៈពេលនៃការឃុំខ្លួនបណ្ដោះមិនអាចលើសពី ២ខែ បានទេបើទោះជាយ៉ាងណា រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះពុំអាចលើសពីពាក់កណ្ដាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[35] ។

ម្យ៉ាងទៀតក្នុងករណីដែលជនត្រូចចោទមានអាយុចាប់ពី **១៦ឆ្នាំ** ដល់ក្រោម **១៨ឆ្នាំ** រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះពុំអាចលើសពី ៤ខែបានទេ ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ពុំអាចលើសពីពាក់កណ្ដាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[36] ។

តាមការបកស្រាយខាងលើមកឃើញថា រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចពន្យារបានឡើយ ប្រសិនបើជនត្រូវចោទជាអនីតិជនទោះបីជាត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិមក៏ដោយ ៕

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២០៩ ។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១៤ ។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១៤ ។

# ជំពូកទី២
# នីតិវិធីពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន

## ១.១. នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន

### ១.១.១. នីតិវិធីសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ត្រូវអនុវត្តអោយបានត្រឹមត្រូវ និងត្រូវគោរពតាមលំដាប់លំដោយនៃនីតិវិធីដូចខាងក្រោម៖

#### ១.១.១.១. កិច្ចបង្ហាញខ្លួនលើកដំបូង

ការបង្ហាញខ្លួនលើកដំបូង ធ្វើឡើងនៅពេលដែលជនត្រូវចោទ ត្រូវបាននាំយកមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដោយមូលហេតុដូចខាងក្រោម៖

- តាមរយៈសេចក្តីសន្និដ្ឋានប្តឹងសុំរបស់ព្រះរាជអាជ្ញា ក្រោយពេលត្រូវបានសមត្ថកិច្ចចាប់ខ្លួន ។
- តាមរយៈការប្រើប្រាស់ដីកា ( ដីកាបង្គាប់អោយចូលខ្លួន, ដីកាបង្គាប់អោយនាំខ្លួន និងដីកាបង្គាប់អោយចាប់ខ្លួន ) ។

នៅពេលជនត្រូវចោទបាននាំយកមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនត្រូវចោទ ប្រាប់ពីរឿងរ៉ាវដែលព្រះរាជអាជ្ញាចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ប្រាប់ពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ និងប្រាប់ពីសិទ្ធិមួយចំនួនដូចជា៖

- សិទ្ធិមានមេធាវី
- សិទ្ធិស្នើសុំអោយបំពេញកិច្ច
- សិទ្ធិនៅស្ងៀមមិនឆ្លើយ (ប្រសិនបើឆ្លើយ ត្រូវយកចម្លើយភ្លាម)
- សិទ្ធិស្នើសុំអោយបិទការស៊ើបសួរនៅក្រោយពេលផុតរយៈពេលមួយឆ្នាំ[37]
- សិទ្ធិអាចប្តឹងមោឃភាពនៃកិច្ចស៊ើបសួរ និងប្តឹងឧទ្ធរណ៍ ។

បន្ទាប់ពីកិច្ចបង្ហាញខ្លួនលើកដំបូងត្រូវបានបញ្ចប់ចៅក្រមស៊ើបសួរនឹងជូនដំណឹងស្តីពីការសម្រេចដាក់អោយស្ថិតក្រោមការត្រួតពិនិត្យ បើជននោះមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿង

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២៨៦ ។

អោយស៊ើបសួររបស់តំណាងអយ្យការ ហើយមានអំណាចអាចដាក់អោយស្ថិតក្រោមការត្រួតពិនិត្យ ប្រសិនបើជននោះមិនមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ តែមានតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ថាបានចូលរួមប្រព្រឹត្តបទល្មើស[38]។ ការដាក់អោយស្ថិតក្រោមការពិនិត្យនាំអោយជននោះទទួលបានឋានៈជាជនត្រូវចោទ ហើយមានអានុភាពអោយចៅក្រមស៊ើបសួរអាចបើកកិច្ចស៊ើបសួរ និងអនុវត្តសេចក្តីសម្រេចនានាលើជនត្រូវចោទដូចជាការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នជាដើម។ បន្ទាប់មកចៅក្រមស៊ើបសួរនឹងបើកកិច្ចពិភាក្សាដេញដោលចំពោះមុខមួយ ដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ។

កិច្ចបង្ហាញខ្លួនលើកដំបូងនេះ ធ្វើឡើងក្នុងទម្រង់ជាកំណត់ហេតុ ដែលមានឈ្មោះថា **កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង** ។

### ១.១.១.២. កិច្ចពិភាក្សាដេញដោលចំពោះមុខ

ដើម្បីបង្ហាញពីតម្លាភាព គណនេយ្យភាព និងជំនឿទុកចិត្តពីសាធារណៈជនលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌលើការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ កិច្ចពិភាក្សាដេញដោលចំពោះមុខត្រូវបានធ្វើឡើងជាចាំបាច់ដើម្បីសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ព្រោះថាការឃុំខ្លួនបណ្តោះអាសន្នមានការប៉ះពាល់យ៉ាងខ្លាំងទៅលើសិទ្ធិ និងសេរីភាពរបស់ជនត្រូវចោទ។

នៅក្នុងកិច្ចពិភាក្សាដេញដោលពីបញ្ហាឃុំខ្លួនចៅក្រមស៊ើបសួរអោយក្រឡាបញ្ជីធ្វើកំណត់ហេតុមួយឈ្មោះថា **កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ** ដើម្បីអោយព្រះរាជអាជ្ញាបង្ហាញនូវសេចក្តីសន្និដ្ឋានរបស់ខ្លួនពីបញ្ហាឃុំខ្លួនជនត្រូវចោទ និងផ្តល់ឱកាសអោយជនត្រូវចោទរួមជាមួយមេធាវីការពារជនត្រូវចោទផ្តល់ការកត់សម្គាល់ ឬធ្វើសេចក្តីសន្និដ្ឋានពីបញ្ហាឃុំខ្លួនតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដើម្បីអោយចៅក្រមស៊ើបសួរ យកធ្វើជាមូលដ្ឋានក្នុងការសម្រេចថា គួរឃុំខ្លួន ឬមិនឃុំខ្លួនជនត្រូវចោទ[39] ។

**ដំណើរការនៃកិច្ចពិភាក្សាដេញដោលចំពោះមុខមានដូចខាងក្រោម៖**

**-ការលើកឡើងរបស់តំណាងអយ្យការ៖** ក្រោយពីការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរតំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំទៅចៅក្រមស៊ើបសួរអោយសម្រេចអំពីការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ដោយលើកឡើងពីភាពចាំបាច់ មូលហេតុ ភស្តុតាង និងសំអាងច្បាប់នានាដើម្បីគាំទ្រទៅលើសេចក្តីសន្និដ្ឋានប្តឹងសុំរបស់ខ្លួន ។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ១២៦ ។
[39] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២០៦ ។

**-ការលើកឡើងរបស់ជនត្រូវចោទ៖** បន្ទាប់ពីព្រះរាជអាជ្ញាបានប្តឹងសុំអោយចៅក្រមស៊ើបសួរសម្រេចពីការឃុំខ្លួន និងក្រោយពីការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ ជនត្រូវចោទត្រូវលើកឡើងពីហេតុផល ឬមូលហេតុនានាដើម្បីជំទាស់នឹងការស្នើរសុំឃុំខ្លួនដោយតំណាងអយ្យការ ។

**-ការលើកឡើងដោយមេធាវីការពារជនត្រូវចោទ៖** មេធាវីការពារជនត្រូវចោទ ត្រូវចូលរួមបង្ហាញអំពីហេតុផល ភស្តុតាង និងមូលហេតុគតិយុត្តិនានា ដើម្បីជំទាស់នឹងការស្នើរសុំឃុំខ្លួនដោយតំណាងអយ្យការ ដើម្បីអោយចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនត្រូវចោទ ។

ក្រោយពេលកិច្ចពិភាក្សាដេញដោលចំពោះមុខត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវសម្រេចអំពីការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ។

#### ១.១.១.៣. ការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន

ដោយយោងទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានផ្តល់សិទ្ធិអំណាចផ្តាច់មុខដល់ចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ នៅដំណាក់កាលស៊ើបសួរ។ ក្រោយពេលស្តាប់ការអះអាងក៏ដូចជាការលើកឡើងអំពី មូលដ្ឋានគតិយុត្តិនានារបស់ភាគីនៅក្នុងកិច្ចពិភាក្សាចំពោះមុខ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា ត្រូវឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវចេញ **ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន** ដោយមានសំអាងហេតុ និង**ដីកាបង្គាប់អោយឃុំខ្លួន** ដើម្បីបញ្ជា និងបង្គាប់ទៅប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនអោយទទួលយកជនត្រូវចោទមកឃុំឃាំង។ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[40] ។

#### ១.១.១.៤. ការអនុវត្តដីកាបង្គាប់អោយឃុំខ្លួន

ក្រោយពេលទទួលបានដីកាបង្គាប់អោយឃុំខ្លួន ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួននូវបុគ្គលដែលមានឈ្មោះនៅក្នុងដីកាបង្គាប់នេះ រហូតទាល់តែបានទទួលការអោយដំណឹងអំពីការដោះលែងអោយមានសេរីភាពវិញ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវរក្សាទុកដើមដីកាបង្គាប់អោយឃុំខ្លួន ឬចុងដីកានេះដែលបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម[41] ។

### ១.១.២. អានុភាពនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នមានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើស ពោលអាស្រ័យទៅតាមលក្ខខណ្ឌនៅក្នុងបទល្មើសដែលចារីបានប្រព្រឹត្ត។ ឆ្លុះបញ្ចាំងតាមរយៈការអនុវត្តជាក់ស្តែង ក្នុង

---

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២០៦ ។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២២២ ។

ករណីដែលមានការផ្តន្ទាទោសដាក់ពន្ធនាគារ ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវរាប់បញ្ចូលដោយស្វ័យប្រវត្តិក្នុងការផ្តន្ទាទោសជាស្ថាពរ ។

**ឧទាហរណ៍៖** ជនត្រូវចោទត្រូវបានជាប់ចោទពីបទ **លួច** ហើយជាប់ឃុំនៅក្នុងពន្ធនាគាររយៈពេល២ ខែ ក្នុងសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្នរយៈពេល ៣ ខែ របស់ចៅក្រមស៊ើបសួរ គិតមកដល់ថ្ងៃប្រកាសសាលក្រម។ នៅពេលប្រកាសសាលក្រមតុលាការបានផ្តន្ទាទោសជននោះ ១ ឆ្នាំដាក់ពន្ធនាគារ ដូចនេះទោសដែលត្រូវអនុវត្តនៅសល់តែ ៩ ខែទៀតប៉ុណ្ណោះ ។

## ១.២. ការមិនឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ

ផ្អែកទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានផ្តល់សិទ្ធិអំណាចផ្តាច់មុខដល់ចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទនៅដំណាក់កាលស៊ើបសួរ ទន្ទឹមនឹងនេះផងដែរចៅក្រមស៊ើបសួរក៏អាចសម្រេចមិនឃុំខ្លួនជនត្រូវចោទផងដែរ ។

### ១.២.១. ការមិនឃុំខ្លួនបណ្តោះអាសន្ន

#### ១.២.១.១. ការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

កាលណាចៅក្រមស៊ើបសួរដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដែលសុំអោយឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ននោះ មិនព្រមធ្វើតាមការសុំអោយឃុំខ្លួននោះទេ ចៅក្រមស៊ើបសួរត្រូវចេញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នដោយមិនចាំបាច់មានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ[42] ។

#### ១.២.១.២. ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំ

កាលណាចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទអោយនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោះលែងអោយនៅក្រៅឃុំ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន[43]។ ជាមួយគ្នានេះផងដែរកាលណាចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះត្រូវរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមអោយដោះលែងជនត្រូវចោទនោះភ្លាម។ ក្នុងករណីដែលមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជ

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២០៧ ។
[43] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១៨ ។

អាជ្ញា អំពីដីកាដោះលែងអោយនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំត្រូវបានរក្សាទុកនៅក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរសម្រេចអំពីបណ្តឹងឧទ្ធរណ៍[44] ។

ការដោះលែងអោយនៅក្រៅឃុំអាចធ្វើឡើងដោយចៅក្រមស៊ើបសួរ តាមបណ្តឹងរបស់ព្រះរាជអាជ្ញា និងតាមបណ្តឹងរបស់ជនត្រូវចោទ ។

### ក. ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចបង្គាប់អោយដោះលែងជនត្រូវចោទអោយនៅក្រៅឃុំវិញបានគ្រប់ពេលវេលា។ កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទអោយនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវជូនព័តមានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងអោយព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរអាចបង្គាប់អោយដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញាទេ តែចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់ពីមូលហេតុបន្ទាន់នៃការដោះលែងនេះ[45] ។

### ខ. ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំតាមបណ្តឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំអោយដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចនៅក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[46] ។

### គ. ការដោះលែងអោយនៅក្រៅឃុំតាមបណ្តឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំអោយដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ កាលណាមានពាក្យសុំ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២៧៦ ។
[45] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១៥ ។
[46] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១៦ ។

នៅក្នុងករណីមានសេចក្តីសម្រេចបដិសេធពាក្យសុំអោយនៅក្រៅឃុំ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១ (មួយ) ខែ។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[47] ។

### ១.២.២. ការត្រួតពិនិត្យតាមផ្លូវតុលាការ

កាលណាចៅក្រមស៊ើបសួរសម្រេចអោយដោះលែងជនត្រូវចោទអោយនៅក្រៅឃុំ ចៅក្រមនេះអាចដាក់ជននោះអោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន[48]។ ចៅក្រមស៊ើបសួរសម្រេចដាក់ជនត្រូវចោទក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយ **ដីកាបង្គាប់អោយដាក់ក្រោមការពិនិត្យតាមផ្លូវតុលាការ**[49]។ ដីកានេះត្រូវជនដំណឹងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ ដែលកាតព្វកិច្ចទាំងនោះមានដូចដែលកំណត់នៅក្នុងមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

#### ១.២.២.១. កាតព្វកិច្ចរបស់ជនត្រូវចោទ

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទអោយស្ថិតក្រោមការាត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះ ត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

ការត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំ អោយគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅៈ

១. មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ ។

២. មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

៣. មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ ។

៤. ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

---

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១៧ ។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២១៨ កថាខណ្ឌទី ៣ ។

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២២៦ កថាខណ្ឌទី ១ ។

៥. ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

៦. ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់ពីអត្តសញ្ញាណ ។

៧. មិនត្រូវបើកបររថយន្ត ។

៨. មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ ។

៩.ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ ។

១០. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់ ។

១១. ត្រូវប្រគល់ខ្លួនអោយពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់អោយស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។ ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្ត នូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ[50] ។

***កំណត់សម្គាល់៖**

អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវដាក់អោយស្ថិតនៅក្រមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ[51] ។

### ១.២.២.២. ការឃុំខ្លួនបណ្តោះអាសន្ន ករណីបំពានកាតព្វកិច្ចដាក់អោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

កាតព្វកិច្ចគឺជាកិច្ចដែលត្រូវធ្វើដែលខានមិនបាន។ ដោយឡែកចំពោះកាតព្វកិច្ចដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តម្រូវអោយជនត្រូវចោទត្រូវតែគោរព បើមិនដូច្នេះទេ សេរីភាពរបស់ជនត្រូវចោទ អាចនឹងបាត់បង់តាមរយៈការសម្រេចឃុំខ្លួនដោយចៅក្រមស៊ើបសួរ ។

ការសម្រេចដាក់ជនត្រូចចោទអោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់ចៅក្រមស៊ើបសួរ នៅដំណាក់កាលស៊ើបសួរ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចដាក់ជនត្រូវចោទអោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មានន័យថាចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ឬសម្រេចដោះលែងជនត្រូវចោទអោយនៅក្រៅឃុំ ដោយតម្រូវអោយជនត្រូវចោទអនុវត្តកាតព្វកិច្ចមួយ ឬច្រើនដូចដែលបានរៀបរាប់នៅ

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២២៣ ។

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២២៤ ។

ផ្នែកខាងលើ។ ក្រៅពីកាតព្វកិច្ចខាងលើចៅក្រមស៊ើបសួរពុំអាចបង្គាប់អោយជនត្រូវចោទគោរពនូវកាតព្វកិច្ចណាផ្សេងទៀតបានឡើយ ។

នៅក្នុងករណីជនត្រូវចោទដែលបានដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានបំពានកាតព្វកិច្ចដែលបានកំណត់ដោយចៅក្រមស៊ើបសួរ ឬគេចវេសពីកាតព្វកិច្ចដោយចេតនា ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នបាន ទោះបីជាទោសដាក់ពន្ធនាគារដែលត្រូវទទួលរងនោះមានចិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទបានជាប់ឃុំបណ្ដោះអាសន្នអស់រយៈពេលអតិបរមាដែលច្បាប់បានកំណត់ក៏ដោយ ។

**កំណត់ចំណាំ៖** នៅក្នុងដីកាសម្រេចដាក់ជនត្រូវចោទអោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរមានអំណាចប្រគល់សិទ្ធិដល់អាជ្ញាធរមានសមត្ថកិច្ច ដូចជាអង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថដើម្បីតាមដានការអនុវត្តកាតព្វកិច្ចរបស់ជនត្រូវចោទ។ ក្នុងករណីជននេះមិនអនុវត្តតាមកាតព្វកិច្ចដែលបានកំណត់នៅក្នុងដីកាសម្រេចនោះ អាជ្ញាធរទទួលបន្ទុករាយការណ៍ភ្លាមដល់ចៅក្រមស៊ើបសួរ ដើម្បីចាត់វិធានការតាមច្បាប់ចំពោះជនត្រូវចោទ។ ក្រៅពីអង្គភាពខាងលើ ចៅក្រមស៊ើបសួរក៏អាចតាមដានដោយផ្ទាល់ចំពោះការអនុវត្តកាតព្វកិច្ចរបស់ចនត្រូវចោទផងដែរ។ម្យ៉ាងទៀតចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ[52] ។

### ក. រយៈពេលនៃការឃុំខ្លួន

រយៈពេលឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីនេះ មិនមានការបែងចែកតាមប្រភេទនៃបទល្មើស ឬទោសទេ គឺត្រូវអនុវត្តតាមយុវភាពរបស់ជនត្រូវចោទ ដែលមានបញ្ជាក់ដូចខាងក្រោម:

- **បើជនត្រូវចោទជានីតិជន៖** ការឃុំខ្លួននេះយូរបំផុតបានត្រឹម ៤ (បួន) ខែ ។
- **បើជនត្រូវចោទជាអនីតិជន៖** ការឃុំខ្លួននេះយូរបំផុតបានត្រឹម ២ (ពីរ) ខែ[53] ។

### ខ. ការសម្រេចពីការឃុំខ្លួន

ក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថា ជនត្រូវចោទគេចវេសដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២២៧ ។
[53] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២៣០ ។

ទោះបីជាទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទបានឃុំខ្លួនអស់រយៈពេលអតិបរមាដែលកំណត់ដោយច្បាប់ក៏ដោយ។ កាលណាចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់ពីជននោះ មិនតែប៉ុណ្ណោះដីកាសម្រេចនេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា[54] ។

### គ. ការអនុវត្តដីកាបង្គាប់អោយឃុំខ្លួន

ដើម្បីអោយ **ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន** មានអានុភាពអនុវត្តបាន ចៅក្រមស៊ើបសួរត្រូវចេញ **ដីកាបង្គាប់អោយឃុំខ្លួន** មួយទៀត ដើម្បីបង្គាប់ទៅប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនអោយទទួលយកជនត្រូវចោទមកឃុំឃាំងក្នុងមណ្ឌលរបស់ខ្លួន ។

### ១.២.២.៣. ការឃុំខ្លួនបណ្តោះអាសន្នក្រោយចេញដីកាដំណោះស្រាយ

ក្រោយពេលដែលចៅក្រមស៊ើបសួរបានសម្រេចបិទបញ្ចប់ការស៊ើបសួរ ចៅក្រមស៊ើបសួរនឹងសម្រេចចេញដីកាដំណោះស្រាយ ដែលអាចជាដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងការចោទប្រកាន់[55] ដីកាសម្រេចនេះមានអានុភាពបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ប៉ុន្តែដើម្បីធានាវត្តមានរបស់ជនត្រូវចោទចាត់ការតាមនីតិវិធី នៅចំពោះមុខចៅក្រមជំនុំជម្រះ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយឡែកមួយពីដីកាដំណោះស្រាយ ដើម្បីរក្សាជនត្រូវចោទអោយនៅបន្តជាប់ឃុំដដែល ។

សេចក្តីសម្រេចនេះនឹងបាត់បង់អានុភាពក្នុងរយៈពេល ៤ (បួន) ខែ មានន័យថាប្រសិនបើជនត្រូវចោទមិនត្រូវបាននាំយកមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះក្នុងអំឡុងពេល ៤ (បួន) ខែទេ ជនត្រូវចោទត្រូវបានដោះលែងអោយនៅក្រៅឃុំជាបណ្តោះអាសន្នដោយឯកឯង[56] ។

## ១.៣. វិធានពិសេសដែលអនុវត្តចំពោះអនីតិជន

### ១.៣.១. គោលការណ៍ និងសិទ្ធិជាមូលដ្ឋានដែលអនុវត្តចំពោះអនីតិជន

ទាក់ទងនឹងចំនុចនេះយើងនឹងធ្វើការបែងចែកជាការបកស្រាយទៅរកចំនុចពីរ ដែលរួមមាន៖ **(១.៣.១.១.)** គោលការណ៍ជាមូលដ្ឋាន និង **(១.៣.១.២.)** សិទ្ធិជាមូលដ្ឋានដែលអនុវត្តចំពោះអនីតិជន ។

---

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២៣០ ។

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២៤៧ កថាខណ្ឌទី ១ ។

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ មាត្រា ២៤៩ ។

### ១.៣.១.១. គោលការណ៍ជាមូលដ្ឋាន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឲ្យមានការគោរពគោលការណ៍ដូចតទៅ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេសធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរិមា
- ត្រូវផ្តល់ឱកាសឲ្យអនីតិជនសម្តែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត
- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀតដែលប៉ះពាល់ដល់បូរភាពរូបរាងកាយរបស់អនីតិជនលើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះដែលវិធានការទាំងឡាយមិនអនុវត្តបាន ឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន និងដែលនាំឲ្យបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព។ ការផ្សព្វផ្សាយរឿងក្តីអាចធ្វើបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ
- សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ[57] ។

### ១.៣.១.២. សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវ

[57] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦ មាត្រា៥ ។

ទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន[58] ។

### ១.៣.២. ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន

#### ១.៣.២.១. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងការដោះលែង

#### ក. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើអនីតិជននោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ បន្ថែមលើបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យ

[58] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦ មាត្រា៦ ។

តាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប
- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប ។[59]

### ខ. ការដោះលែងឲ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយគំនិតផ្តួចផ្តើមរបស់ខ្លួន។ ចៅក្រមស៊ើបសួរដែលមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

[59] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៩ កក្កដា ២០១៦ មាត្រា៤០ ។

ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុងបម្រុងអនីតិជនដែលអាចសុំឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ។ មេធាវីអាចសុំដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានដោយមានការយល់ព្រមពីអនីតិជន។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។[60]

**១.៣.២.២. ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ**

មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសរយៈពេល ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ ។

ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់មានអានុភាពនាំឲ្យដោះលែងអនីតិជនដែលជាប់ឃុំទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកដំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលស្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវស្នើសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ[61] ៕

[60] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦ មាត្រា៩១ ។

[61] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦ មាត្រា៩២ ។

# សេចក្តីសន្និដ្ឋាន

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានធ្វើការបញ្ញត្តឡើងនូវនីតិវិធីផ្សេងៗគ្នាដើម្បីធ្វើការអនុវត្ត ដោយធ្វើយ៉ាងណាស្វែងរកអោយឃើញនូវអត្ថិភាពនៃបទល្មើសយ៉ាងពិតប្រាកដ ដោយអ្នកនីតិបញ្ញត្តិបានធ្វើការបែងចែកជាដំណាក់កាលផ្សេងៗពីគ្នាដូចជា ដំណាក់កាលមន្រ្តីនគរបាលយុត្តិធម៌ ដំណាក់កាលនៃការស្រាវជ្រាវ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលនៃការជំនុំជម្រះ។ ដោយឡែកនៅក្នុងការសិក្សានៃអត្ថបទសារណានេះ យើងធ្វើការសិក្សានៅក្នុងដំណាក់កាលនៃចៅក្រមស៊ើបសួរដោយជ្រើសយកតែផ្នែកតូចមួយនៃដំណាក់កាលចៅក្រមស៊ើបសួរតែប៉ុណ្ណោះ គឺ ***ការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ*** ។

យើងឃើញថាតួអង្គរបស់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលនៃការស៊ើបសួរ គឺដើម្បីស្វែងរកការពិត និងស្វែងរកភស្តុតាងនៃសំណុំរឿងព្រហ្មទណ្ឌ មានតម្លាភាព និងសុក្រឹត្យភាព ដោយរក្សាបាននូវស្ថិរភាពនៃនីតិវិធីក្នុងរឿងក្តី គោរពបាននូវសិទ្ធិរបស់បុគ្គលពាក់ព័ន្ធ ព្រមទាំងបានផ្តល់នូវភស្តុតាងយ៉ាងប្រត្យក្សចំពោះអង្គហេតុដែលបានកើតឡើង។ ការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងនៅក្នុងក្រមនីតិវិធី គឺជាវិធានការនិរន្តរាយមួយក្នុងចំណោមផ្សេងៗទៀតដែលអនុញ្ញាតអោយចៅក្រមស៊ើបសួរ អាចធ្វើទៅបានក្នុងគោលបំណងដើម្បីធានានៅកិច្ចនៃការស៊ើបសួររបស់ខ្លួនប្រព្រឹត្តទៅបានដំណើរការល្អប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការស្វែងរកអោយឃើញពីអត្ថិភាពនៃអង្គហេតុបង្ហាញអោយឃើញពីពិរុទ្ធភាពរបស់ជនត្រូវចោទ។ បើទោះបីជាចៅក្រមស៊ើបសួរធ្វើការស៊ើបសួរដោយស៊ើបសួរទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ប៉ុន្តែការឃុំខ្លួនបណ្តោះអាសន្ននៅតែជាការចាំបាច់។ ការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទមិនមែនមានន័យថាជននោះមានទោសនោះទេ ពីព្រោះថាវាគ្រាន់តែជាវិធានការដើម្បីឃាត់ជនត្រូវចោទអោយនៅក្នុងពន្ធនាគារដើម្បីរកអោយឃើញថាជននោះមានទោស ឬគ្មានតែប៉ុណ្ណោះ។ មួយវិញទៀត ទាល់តែមានការប្រកាសជាស្ថាពរដោយសារដីកា ឬសាលក្រមជាស្ថាពរប៉ុណ្ណោះទើប អាចបញ្ជាក់ថាជនណាម្នាក់មានទោសពីបទល្មើសណាមួយ ។

ក្នុងការឃុំខ្លួនបណ្តោះអាសន្ននេះ ចៅក្រមស៊ើបសួរត្រូវធ្វើការពិចារណាក៏ដូចជាធ្វើការសាកសួរព័ត៌មានអោយបានគ្រប់ជ្រុងជ្រោយមុនសិន មុននឹងឈានទៅដល់ការសម្រេចការឃុំខ្លួនបណ្តោះអាសន្ន។ ទន្ទឹមនឹងនេះផងដែរ ចៅក្រមស៊ើបសួរគប្បីពិនិត្យអំពីលក្ខខណ្ឌមួយចំនួនដែលត្រូវបានកំណត់ដោយច្បាប់ក្នុងគោលដៅធានាអោយបាននីត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្ន ។

ទោះបីជាគោលការណ៍សេរីភាពត្រូវបានទទួលស្គាល់ និងយកមកអនុវត្តប៉ុន្តែនៅក្នុងករណីចាំបាច់ការឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរ គប្បីពិនិត្យនូវលក្ខខណ្ឌមួយចំនួនដែលទាក់ទិនទៅនឹងការឃុំខ្លួនបណ្តោះអាសន្នដូចជា លក្ខខណ្ឌទាក់ទងទៅនឹងបទល្មើសដែលត្រូវបានចោទប្រកាន់ លក្ខខណ្ឌទាក់ទងទៅនឹងទោស ព្រមទាំងលក្ខខណ្ឌទាក់ទងទៅនឹងអាយុរបស់ជនត្រូវចោទក៏ជាចំណុចសំខាន់ដែរសម្រាប់ចៅក្រមស៊ើបសួរ ដែលត្រូវតែដឹងដោយហេតុអាយុនេះជាមូលដ្ឋានយ៉ាងសំខាន់ក្នុងការសម្រេចពីការឃុំខ្លួន និងរយៈពេលនៃការឃុំខ្លួនដែលត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ។ អ្វីដែលជាចំណុចពិសេសជាងនេះទៅទៀតនោះ ការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទមានអាយុតិចជាង១៤(ដប់បួន) ឆ្នាំ មិនត្រូវបានអនុញ្ញាតនោះឡើយ ។

ក្រៅអំពីលក្ខខណ្ឌខាងលើចៅក្រមស៊ើបសួរ ត្រូវតែធ្វើការបង្ហាញខ្លួនជាលើកដំបូងចំពោះជនត្រូវចោទដោយអាចមានវត្តមានរបស់តំណាងអយ្យការ និងមេធាវីការពារសិទ្ធិអោយជនត្រូវចោទប្រសិនបើមាន ក្នុងគោលបំណងដើម្បីធ្វើការផ្ទៀងផ្ទាត់ពីអត្តសញ្ញាណរបស់ជនត្រូវចោទ ជៀសវាងនៅការភ័ន្តច្រឡំណាមួយដែលអាចកើតមានឡើងជាយថាហេតុ។ ទន្ទឹមនឹងការបង្ហាញខ្លួនជាលើកដំបូងចៅក្រមស៊ើបសួរត្រូវធ្វើការពិភាក្សាដេញដោលចំពោះមុខក្នុងការសាកសួរពីព័ត៌មានមួយចំនួនដែលយល់ឃើញថាជាការចាំបាច់ក្នុងការសម្រេចពីការឃុំខ្លួន ឬមិនឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ។

ក្រោយពីការបញ្ចប់កិច្ចទាំងពីរនេះរួចហើយ ប្រសិនបើចៅក្រមស៊ើបសួរគាត់យល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នជាការចាំបាច់ គាត់ត្រូវតែបង្ហាញពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលជាមូលហេតុទូទៅ ឬក៏មូលហេតុពិសេសដែលជាការគេចវេសពីការត្រួតពិនិត្យតាមផ្លូវតុលាការ។ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវធ្វើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងចេញដីកាបង្គាប់អោយឃុំខ្លួនទៅលើជនត្រូវចោទដែលជាកម្មវត្ថុនៃការឃុំខ្លួន ។

សរុបសេចក្តីមក បើទោះបីជាការឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឡើងដោយចៅក្រមស៊ើបសួរមានលក្ខណៈកាត់បន្ថយនូវសិទ្ធិសេរីភាពរបស់ជនត្រូវចោទក្តី ប៉ុន្តែក៏អាចបកស្រាយបានថាការអនុវត្តវិធាននេះគឺធ្វើឡើងក្នុងគោលបំណងរក្សាសុវត្ថិភាព និងសន្តិសុខចំពោះជនត្រូវចោទ ហើយវាពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងកិច្ចដំណើរការនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ឬ សង្គម និងបង្ហាញពីការរក្សាបាននូវស្មារតីនៃរដ្ឋធម្មនុញ្ញ ដែលមានតែស្ថាប័នតុលាការមួយគត់ដែលមានសិទ្ធិក្នុងការសម្រេចសេចក្តី ៕

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងតាមរយៈការសាកសួរមន្ត្រីដែលអនុវត្តច្បាប់នៅសាលាដំបូងរួចមកយើងសង្កេតឃើញថា គប្បីមានការកែតម្រូវនូវចំណុចមួយចំនួនក្នុងគោលបំណងដើម្បីឲ្យការអនុវត្តន៍កាន់តែមានប្រសិទ្ធភាពតាមការកំណត់ក្នុងទ្រឹស្តី នឹងទទួលបានទំនុកចិត្តពីសាធារណៈជន ក៏ដូចជាជនត្រូវចោទ យើងខ្ញុំសូមលើកយកអានុសាសន៍មួយចំនួនដូចខាងក្រោម ៖

- ធានាអោយបានគោលការណ៍សេរីភាពរបស់ជនត្រូវចោទ ពោលគឺជៀសវាងនៅក្នុងករណីមួយចំនួនដែលការឃុំខ្លួនបណ្តោះអាសន្នមិនមែនជាការចាំបាច់ ។
- ចំពោះកិច្ចបង្ហាញខ្លួនលើកដំបូងគួរតែធ្វើដាច់ដោយឡែក ហើយត្រូវប្រាប់ពីសិទ្ធិដែលធានាដោយក្រមនីតិវិធីព្រហ្មទណ្ឌទាំងអស់ដល់ជនត្រូវចោទ ដើម្បីឲ្យគាត់មានលទ្ធភាពការពារខ្លួនតាមការកំណត់របស់ច្បាប់ ។
- ចំពោះនីតិវិធីនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ន គួរអនុវត្តឲ្យបានត្រឹមត្រូវតាមការកំណត់នៅក្នុងទ្រឹស្តីដោយ **ទី១**-ត្រូវធ្វើកិច្ចបង្ហាញខ្លួនលើកដំបូង, **ទី២**-កិច្ចពិភាក្សាដេញដោលចំពោះមុខ និង**ទី៣**-ទើបឈានដល់ការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្នលើការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ។
- ចៅក្រមស៊ើបសួរក្រោយពីទទួលបានសំណុំរឿងព្រហ្មទណ្ឌ ដែលត្រូវបានចាត់តាំងដោយប្រធានតុលាការដោយដីកាសម្រេចចាត់តាំងចៅក្រមស៊ើបសួរ ត្រូវដំណើរការនៃនីតិវិធីបង្ហាញខ្លួនជាលើកដំបូង និងធ្វើការពិភាក្សាដេញដោលចំពោះមុខព្រោះថានីតិវិធីនេះ គឺមានភាពចាំបាច់បំផុតដោយហេតុចៅក្រមស៊ើបសួរអាចស្វែងយល់ និងដឹងពីព័ត៌មានបន្ថែមអំពីជនត្រូវចោទក្នុងការវិនិច្ឆ័យថាតើខ្លួនត្រូវសម្រេចឃុំខ្លួនជនត្រូវចោទ ឬ មិនឃុំ។
- ចំពោះកិច្ចពិភាក្សាដេញដោលចំពោះមុខ គួរបើកជាសវនាការមុនអង្គសេចក្តីមួយនៅសាលសវនាការជាសាធារណៈ ហើយធ្វើយ៉ាងណាត្រូវធានាឲ្យបាននូវវត្តមានរបស់ភាគីពាក់ព័ន្ធចូលរួម ទាំងតំណាងអយ្យការ មេធាវី និងជនត្រូវចោទ ដើម្បធ្វើការពិភាក្សាដេញដោលតទល់ពីមូលហេតុ ក៏ដូចជាលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន។ ម្យ៉ាងទៀតវានឹងធ្វើឲ្យជនត្រូវចោទអស់ចិត្ត និងទទួលយកចំពោះសេចក្តីសម្រេចឃុំខ្លួនដែលចេញដោយចៅក្រមស៊ើបសួរ មិនតែប៉ុណ្ណោះ វានឹងធានាបានថាប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវចំពោះជនត្រូវចោទ ។

- ដើម្បីធានាឲ្យបាននូវសវនាកាមុនអង្គសេចក្តីប្រព្រឹត្តទៅឲ្យបានរលូន ដោយសារតែបញ្ហាកកស្ទះសំណុំរឿងច្រើនពេកនៅតាមសាលាដំបូងនីមួយៗ គួរបន្ថែមចំនួនចៅក្រម និងព្រះរាជអាជ្ញា ដើម្បីមានពេលវេលាគ្រប់គ្រាន់ធ្វើចំណាត់ការសំណុំរឿងត្រឹមត្រូវតាមការកំណត់ក្នុងនីតិវិធីច្បាប់ ។
- ចំពោះទ្រឹស្តីទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ គួរតែកំណត់ឲ្យបានច្បាស់លាស់អំពីនីតិវិធីនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជាពិសេសនីតិវិធីនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ន នៅពេលពេលជនត្រូវចោទត្រូវបានយកមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ បន្ទាប់ពីបានបំពាននឹងកាតព្វកិច្ចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

ក្រៅពីនេះ ក្រោយពេលដែលចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទរួចហើយ ជននោះត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅក្នុងពន្ធនាគារដើម្បីរងចាំការកាត់ក្តីដោយចៅក្រមជំនុំជម្រះ។ ទន្ទឹមនឹងនោះខ្ញុំបាទយល់ឃើញថា៖

- ជនត្រូវចោទដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារនោះ គឺមានភាពខ្វះខាតនៅជំនួយផ្នែកច្បាប់ ហើយពេលខ្លួនពួកគាត់ក៏មានជីវភាពខ្វះខាតដែលធ្វើអោយគាត់គ្មានលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិរបស់គាត់តាមផ្លូវច្បាប់ ដូចជាសិទ្ធិក្នុងការស្នើសុំនៅក្រៅឃុំ សិទ្ធិក្នុងការប្តឹងជិតចិត្ត សិទ្ធិក្នុងការប្តឹងទៅនឹងដីកាផ្សេងៗរបស់ចៅក្រមស៊ើបសួរដែលច្បាប់បានផ្តល់ជូនគាត់។
- គួរការពន្លឿននីតិវិធី ចៅក្រមស៊ើបសួរគួរផ្តល់អាទិភាពចំពោះសំណុំរឿងព្រហ្មទណ្ឌទាំងឡាយណាដែលមានជនត្រូវចោទ ដែលនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នជាពិសេស គឺសំណុំរឿងដែលមានជនត្រូវចោទជាអនីតិជនជាដើម ព្រមទាំងធានាឲ្យមានការសហការបានល្អជាមួយស្ថាប័នដែលពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការស៊ើបសួរ ។

# ឯកសារយោង


## ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧ ។
- ច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤៧ មាត្រា៣៧២ និងមាត្រា៣៨២, នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ២០១៣ ។
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦ ។

## ២. សៀវភៅ និងឯកសារផ្សេងៗ

- លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។
- សៀវភៅសន្និសីទស្តីពី ការណែនាំពីការអនុវត្តដីការសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងសារាចរនានាស្តីពីជម្រើសផ្សេងទៀត ក្រៅពីការឃុំខ្លួន ចុះថ្ងៃទី ២៥-២៦ ខែមីនា ឆ្នាំ ២០១៤ ។
- សៀវភៅ មេរៀននីតិវិធីព្រហ្មទណ្ឌ របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។
- របាយការណ៍កម្មសិក្សារបស់សិស្សក្រឡាបញ្ជីជំនាន់ទី៤ ឡី សិរីរិទ្ធិ ស្តីពី "ការឃុំខ្លួនបណ្តោះអាសន្ន" ឆ្នាំសិក្សា ២០១៥-២០១៦ ។
- ឯកសារស្តីពី "សិទ្ធិរបស់ជនត្រូវចោទ" របស់សកលវិទ្យាល័យន័រតុន ។
- ហ៊ែល ចំរើន, *មរតកយុត្តិធម៌ខ្មែរ* (ភ្នំពេញ៖ បោះពុម្ពផ្សាយដោយរោងពុម្ព ភ្នំពេញ, ឆ្នាំ ២០១០ ។

# បញ្ជីឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ០១ | ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ |
| ០២ | កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង |
| ០៣ | កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ |
| ០៤ | កំណត់ហេតុសួរចម្លើយជនត្រូវចោទ |
| ០៥ | ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន |
| ០៦ | ដីកាបង្គាប់ឲ្យឃុំខ្លួន |
| ០៧ | ពាក្យសុំនៅក្រៅឃុំខ្លួនបណ្តោះអាសន្ន |
| ០៨ | ដីកាបញ្ជូនឲ្យឆ្លើយ |
| ០៩ | ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន |
| ១០ | ដីកាបង្គាប់ឲ្យដោះលែង |
| ១១ | ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន |
| ១២ | ដីកាសម្រេចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ |
| ១៣ | ដីកាបង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួន |
| ១៤ | ដីកាបង្គាប់ឲ្យចាប់ខ្លួន |
| ១៥ | ដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ |
| ១៦ | ដីកាសម្រេចពន្យាពេលឃុំខ្លួនបណ្តោះអាសន្ន |
| ១៧ | ដីកាបញ្ជូនទៅជំនុំជម្រះ |